រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ឯកសារជំនួយស្មារតី

## ស្តីពី

## វិធីសាស្ត្របញ្ជ្រាបភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ប្រកបដោយបរិយាប័ន្នសង្គមក្នុងកិច្ចដំណើរការ កសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

ខែមេសា ឆ្នាំ២០១៧

# អារម្ភកថា

បច្ចុប្បន្ន មានប្រទេសជាច្រើននៅក្នុងពិភពលោកបាន និងកំពុងប្រឈមមុខនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍។ ជាក់ស្តែង ប្រទេសកម្ពុជាយើង គឺជាប្រទេសមួយក្នុងចំណោមប្រទេសទាំងនោះ ដែលកំពុងជួបប្រទះនឹងបញ្ហានៃការប្រែប្រួលអាកាសធាតុដូចជា ការប្រែប្រួលសីតុណ្ហភាព និងការផ្លាស់ប្តូររបបទឹកភ្លៀងបានកើតមានឡើងជាច្រើនទសវត្សរ៍មកហើយ ពិសេសនៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ផែនការយុទ្ធសាស្ត្រស្តីពីវិធានការទប់ទល់នឹងការប្រែប្រួលអាកាសធាតុសម្រាប់រយៈពេល១០ឆ្នាំ (២០១៤-២០២៣) បានប៉ាន់ប្រមាណថា សីតុណ្ហភាពនឹងនៅតែបន្តកើនឡើង ហើយបរិមាណទឹកភ្លៀងនៅរដូវប្រាំងក៏នឹងថយចុះ ព្រមទាំងនឹងមានការពន្យារពេលនៃការចាប់ផ្តើមនូវរដូវវស្សាទៀតផង។ អាស្រ័យហេតុនេះ ផែនការយុទ្ធសាស្ត្របានកំណត់ និងដាក់ចេញនូវវិធានការសមស្រប និងចាំបាច់នានាទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបចំពោះបញ្ហាទាំងនេះ។ ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប. ដោយមានជំនួយបច្ចេកទេសពីកម្មវិធីស្បៀងអាហារពិភពលោកប្រចាំនៅកម្ពុជា និងទទួលបានការគាំទ្រមូលនិធិពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក សម្រាប់លើកកម្ពស់ភាពស៊ាំ និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងតំបន់ទន្លេមេគង្គ (Mekong ARCC) ដែលមានមូលដ្ឋាននៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៏បានរៀបចំឯកសារជំនួយស្មារតីនេះឡើង ដើម្បីផ្តល់ជាតុចូលបន្ថែមជាឧបករណ៍ និងវិធីសាស្ត្រនានាសម្រាប់ការប្រើប្រាស់ក្នុងការ



វិភាគ និងការកំណត់បញ្ហា និងអាទិភាពនានាពាក់ព័ន្ធនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដោយមានការចូលរួមប្រកបដោយបរិយាប័ន្នសង្គមពីប្រជាពលរដ្ឋគ្រប់ក្រុម និងអ្នកពាក់ព័ន្ធនានានៅក្នុងសហគមន៍ ព្រមទាំងការពិនិត្យពិចារណា និងការឆ្លើយតបទៅនឹងតម្រូវការទាំងនោះ។

ឯកសារជំនួយស្មារតីនេះ ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ តាមរយៈសិក្ខាសាលាពិគ្រោះយោបល់នានា ដែលបានរៀបចំឡើងនៅក្នុងអំឡុងខែឧសភា និងមិថុនា ឆ្នាំ២០១៦ និងការអនុវត្តសាកល្បងជាក់ស្តែងនៅក្នុងឃុំគោលដៅចំនួន១២ ក្នុងស្រុកចំនួន៦នៃខេត្តកំពង់ធំ សៀមរាប និងពោធិ៍សាត់ក្នុងអំឡុងខែសីហា ឆ្នាំ២០១៦។

លេខាធិការដ្ឋាន គ.ជ.អ.ប. សង្ឃឹមថា ឯកសារជំនួយស្មារតីនេះនឹងរួមចំណែកជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការវិភាគបញ្ហាតម្រូវការ និងការកំណត់គម្រោងអាទិភាពពាក់ព័ន្ធការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីបញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់របស់ខ្លួន។

រាជធានីភ្នំពេញ ថ្ងៃទី២៥ខែមេសា ឆ្នាំ២០១៧

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.**

**សក់ សេដ្ឋា**

# មាតិកា

១. សេចក្តីផ្តើម ៤
២. អំពីសៀវភៅណែនាំ ៧
៣. ចំណុចត្រូវយកចិត្តទុកដាក់ ៨
៤. និយមន័យ ៨
៥. គោលការណ៍ ១០
៥.១.គោលការណ៍សម្រាប់ការកសាងផែនការឃុំ សង្កាត់ ១០
៥.២.គោលការណ៍សម្រាប់ការបញ្ជ្រាបភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងកិច្ចដំណើរការកសាងអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ១១
៦. សកម្មភាព និងយន្តការ ១២
៦.១. សកម្មភាព ១២
៦.២. យន្តការ ១៣
៧. យុទ្ធសាស្ត្រអនុវត្ត ១៧
៧.១. ការវិភាគ និងការកំណត់ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅថ្នាក់ឃុំ សង្កាត់ ១៧
៧.២. ការវិភាគ និងការកំណត់ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើក្រុមជនងាយរងគ្រោះ ២២
៧.៣. ការរៀបចំប្រតិទិនរដូវកាល ២៤
៧.៤. ការកំណត់បញ្ហា តម្រូវការ និងដំណោះស្រាយ ២៥
៨. កិច្ចដំណើរការអនុវត្ត ២៨
ឧបសម្ព័ន្ធ
ឧបសម្ព័ន្ធ១ ៖ ឧបករណ៍វិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ៣១
ឧបសម្ព័ន្ធ២ ៖ ការរៀបចំផែនទីសេវាសង្គម ៣៧
ឧបសម្ព័ន្ធ៣ ៖ ការរៀបចំប្រតិទិនរដូវកាល ៤៦



# ឯកសារជំនួយស្មារតី

## ស្តីពី

## វិធីសាស្ត្របញ្ជ្រាបភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ប្រកបដោយបរិយាប័ន្នសង្គមក្នុងកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

### ១. សេចក្តីផ្តើម

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ការប្រែប្រួលអាកាសធាតុបានជះឥទ្ធិពលជាអវិជ្ជមាន និងបង្កបញ្ហាជាច្រើនដល់ប្រទេសកម្ពុជាយើងមានដូចជា គ្រោះរាំងស្ងួត ទឹកជំនន់ ការផ្លាស់ប្តូររបបទឹកភ្លៀង ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ និងរន្ទះជាដើម។

ផលប៉ះពាល់ ដែលកើតចេញពីបញ្ហានៃការប្រែប្រួលអាកាសធាតុនាពេលថ្មីៗនេះរួមមានដូចខាងក្រោម ៖

| ប្រភេទគ្រោះធម្មជាតិ | ផលប៉ះពាល់ |
|---|---|
| ភាពរាំងស្ងួតធ្ងន់ធ្ងរ | ការពន្យារពេលនៃភាពរាំងស្ងួតនៅចុងរដូវប្រាំងនឹងផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់ធនធានជលផល។ ក្នុងអំឡុងរដូវប្រាំង បរិមាណទឹកបានថយចុះប្រមាណពី ៣ ទៅ១០%។ |
| ការកើនឡើងសីតុណ្ហភាព | កម្រិតសីតុណ្ហភាពកើនឡើងពីចាប់ពី២ ទៅ ៤ អង្សារធៀបជាមួយនឹងកម្រិតខ្ពស់បំផុតប្រចាំថ្ងៃ ដែលមានកម្រិតប្រមាណ ៣៣ អង្សារកាលពីខែមីនា។ ដោយសារបញ្ហាការប្រែប្រួលអាកាសធាតុ កម្រិតខ្ពស់បំផុតនៃសីតុណ្ហភាពប្រចាំថ្ងៃកើនដល់ ៣៥អង្សារ នៅក្នុងអំឡុងខែមីនា និងមេសា ដែលការកើនឡើងនេះនឹង |

| ប្រភេទគ្រោះធម្មជាតិ | ផលប៉ះពាល់ |
|---|---|
| | ផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងវិស័យកសិកម្ម ពិសេសដំណាំស្រូវ សត្វពាហនៈ និងការចិញ្ចឹមសត្វផ្សេងៗ។ |
| ទឹកជំនន់ | ទឹកជំនន់បង្កឲ្យមានទឹកជន់លិច និងផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងនៅភាគកណ្តាល និងភាគខាងត្បូងនៃខេត្តកំពង់ធំ។ តាមរយៈការព្យាករណ៍កម្ពស់ទឹកជំនន់អាចនឹងកើនឡើងដល់១៨%។ ដំណាំស្រូវ សណ្តែកសៀង និងដំឡូងមីបានរងផលប៉ះពាល់ខ្លាំងជាងគេដោយសារឧប្បត្តិហេតុកំដៅឡើងខ្លាំង និងមានគ្រោះទឹកជំនន់។ |
| ការផ្លាស់ប្តូររបបទឹកភ្លៀង | ការធ្លាក់ភ្លៀងខ្លាំងៗបានកើតឡើងកាន់តែញឹកញាប់ដោយកើនឡើង១១% ក្នុងអំឡុងរដូវវស្សាកន្លងទៅ។ ឧទាហរណ៍ ៖ កម្ពស់ទឹកភ្លៀងកើនដល់៤០មម នៅក្នុងខែកញ្ញា ដែលកំណើននេះបានផ្តល់ផលប៉ះពាល់ដល់ដំណាំដំឡូងមី និងសណ្តែកសៀង។ |

ប្រភព ៖ ឯកសារស្តីពីការចែករំលែកការយល់ដឹង និងសេចក្តីសង្ខេបអំពីលក្ខណៈវិទ្យាសាស្ត្រនៃអាកាសធាតុ, *WFP Cambodia-Mekong ARCC BKK,* ខែកុម្ភៈ ឆ្នាំ២០១៥។

ជាក់ស្តែង ក្នុងអំឡុងខែមេសា-ឧសភា ឆ្នាំ២០១៦នេះ ប្រទេសកម្ពុជាបានជួបប្រទះបញ្ហាគ្រោះរាំងស្ងួត ដែលបានអូសបន្លាយអស់រយៈពេលជាយូរ និងមានការកើនកំដៅខ្លាំងដែលជាហេតុធ្វើឲ្យប្រភពទឹកនានាដូចជា ស្រះ ប្រឡាយ ស្ទឹង បឹងបួរនានា ត្រូវរីងស្ងួតនៅស្ទើរគ្រប់ទីកន្លែងទូទាំងប្រទេស និងបានបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់ការដាំដុះ និងការចិញ្ចឹមសត្វរបស់កសិករ។





រូបភាពបង្ហាញអំពីស្ថានភាពគ្រោះរាំងស្ងួតនៅកម្ពុជា

ដើម្បីរួមចំណែកក្នុងការដោះស្រាយបញ្ហានានា ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលបានអនុម័តផែនការយុទ្ធសាស្ត្រស្តីពីវិធានការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ សម្រាប់រយៈពេល១០ឆ្នាំ (២០១៤-២០២៣) ព្រមទាំងបានស្នើឲ្យចាត់វិធានការនានាជាបន្ទាន់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ជាទូទៅ ប្រជាពលរដ្ឋ ឬក្រុមជនដែលងាយទទួលរងគ្រោះពីការប្រែប្រួលអាកាសធាតុភាគច្រើន គឺជាស្ត្រីដែលរស់នៅដោយពឹងផ្អែកជាសំខាន់លើការប្រកបមុខរបរក្នុងវិស័យកសិកម្ម និងអាស្រ័យផលលើធនធានធម្មជាតិ។ ជាងនេះទៀត គឺកុមារងាយទទួលរងគ្រោះពីការប្រែប្រួលអាកាសធាតុនេះ ព្រោះពួកគេរស់នៅដោយពឹងផ្អែក

ទាំងស្រុងលើការយកចិត្តទុកពីគ្រួសាររបស់ខ្លួន។ ជារួម ក្រុមជនងាយរងគ្រោះទាំងនេះមានហានិភ័យខ្ពស់ក្នុងការទទួលរងនូវជំងឺនានា ដោយសារពួកគាត់ពុំមានធនធាន និងសមត្ថភាពគ្រប់គ្រាន់ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ រួមបញ្ចូលទាំងការត្រៀមរៀបចំខ្លួនជាមុនក្នុងការទប់ទល់នឹងគ្រោះអាសន្ន ដែលកើតចេញពីការប្រែប្រួលអាកាសធាតុទាំងនេះផងដែរ។ អាស្រ័យហេតុនេះ ផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំនេះ បានតម្រូវឲ្យមានការយកចិត្តទុកដាក់ការបញ្ជ្រាបយេនឌ័រ ក្នុងវិធានការនានានៃការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

## ២. អំពីសៀវភៅណែនាំ

ដើម្បីរួមចំណែកលើកកម្ពស់ចំណេះដឹង និងជំនាញ ព្រមទាំងជួយក្រុមប្រឹក្សាឃុំ សង្កាត់ ពិសេស គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់ (គ.ផ.ថ.) ក្នុងការកំណត់ និងដាក់បញ្ចូលបញ្ហានានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ យេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមក្នុងកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់របស់ខ្លួន លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំឯកសារជំនួយស្មារតីនេះឡើង ដែលរួមបញ្ចូលនូវវិធីសាស្ត្រ និងឧបករណ៍នានា សម្រាប់ការប្រើប្រាស់ជាធាតុចូលបន្ថែមលើសេចក្តីណែនាំដែលមានស្រាប់ និងប្រកបដោយភាពបត់បែនស្របតាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាននីមួយៗ។ សៀវភៅណែនាំ ឬឯកសារជំនួយស្មារតីនេះបរិយាយអំពីឧបករណ៍សំខាន់ៗ



មួយចំនួនសម្រាប់ប្រើប្រាស់ក្នុងការពិភាក្សា និងការវិភាគផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ព្រមទាំងការកំណត់អាទិភាពនៅថ្នាក់ភូមិជាមួយក្រុមជនងាយរងគ្រោះនានាមុន ឬក្នុងពេលរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ (ជំហានទី១)។

## ៣. ចំណុចត្រូវយកចិត្តទុកដាក់

ក្នុងការប្រើប្រាស់សៀវភៅណែនាំនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ផ.ថ. ត្រូវយកចិត្តទុកដាក់លើចំណុចជាគន្លឹះចំនួន ២ ដើម្បីពិចារណា និងដាក់បញ្ចូលទៅក្នុងគម្រោង សកម្មភាពនានានៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់របស់ខ្លួន។ ចំណុចជាគន្លឹះទាំងពីរនោះរួមមាន ៖

- ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និង
- ការលើកកម្ពស់យេនឌ័រ បរិយាប័ន្ននិងសមធម៌សង្គម។

## ៤. និយមន័យ

- **ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ** គឺជាសកម្មភាពដែលយើងត្រូវធ្វើ បានគ្រោងទុក ឬមិនបានគ្រោងទុក និងតម្រូវឲ្យយើងធ្វើការសម្របខ្លួន ស្របតាមមុខសញ្ញាគ្រោះថ្នាក់នីមួយៗបណ្តាលមកពីអាកាសធាតុ។ ការបន្សាំគឺជាការសម្របខ្លួននៅក្នុងប្រព័ន្ធធម្មជាតិ ឬប្រព័ន្ធនៃការឆ្លើយតបនឹងកត្តាប្រែប្រួលអាកាសធាតុ ក្នុងពេលបច្ចុប្បន្ន ឬទៅអនាគត។ ការសម្របខ្លួន ឬការអនុវត្តសកម្មភាពទាំងនេះ មានគោលដៅកាត់បន្ថយគ្រោះថ្នាក់នានាដែល

បង្កដោយកត្តាទាំងនេះ (ដកស្រង់ចេញពីសៀវភៅស្តីពីការវាយតម្លៃអំពីការកាត់បន្ថយភាពងាយរងគ្រោះ UNDP ២០១៥)។

<u>**កំណត់សម្គាល់**</u> ៖ សម្រាប់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុទាមទារឲ្យមានការគិតគូរ ឲ្យបានគ្រប់ជ្រុងជ្រោយអំពីផលប៉ះពាល់នានាដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងសកម្មភាពជាអាទិភាពនានាដែលក្រុង ស្រុក និងឃុំ សង្កាត់ ត្រូវរៀបចំ និងអនុវត្ត ដើម្បីកាត់បន្ថយហានិភ័យនៃការប្រែប្រួលអាកាសធាតុទាំងនេះ។

- **បរិយាប័ន្ន** ៖ ក្នុងបរិបទកំណែទម្រង់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ពាក្យ "បរិយាប័ន្ន" មានន័យថា ជាការលើកកម្ពស់ស្ថានភាពរបស់បុគ្គល និងក្រុមនានាក្នុងការចូលរួម និងការទទួលផលពីសកម្មភាពនានារបស់សង្គមដោយគ្មានការរើសអើង។
- **សមធម៌សង្គម** មានន័យថា ៖
  - ជាការលើកកម្ពស់សិទ្ធិរបស់ជនគ្រប់រូបនៅក្នុងសង្គមក្នុងការទទួលបាន និងការប្រើប្រាស់ប្រកបដោយសមធម៌នូវផលប្រយោជន៍ពីការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
  - ជាការលើកកម្ពស់សិទ្ធិរបស់ជនគ្រប់រូប ក្នុងការចូលរួមយ៉ាងពេញលេញជាមួយសកម្មភាពនានា ដែលពាក់



ព័ន្ធនឹងសង្គមកិច្ច នយោបាយ សេដ្ឋកិច្ច វប្បធម៌... នៅក្នុងសង្គម ឬសហគមន៍របស់ពួកគាត់។
  - ជាការលើកកម្ពស់សិទ្ធិរបស់បុគ្គលម្នាក់ៗ ក្នុងការធ្វើសេចក្តីសម្រេចចិត្តសម្រាប់ខ្លួនឯង ដើម្បីសម្រេចបាននូវសេចក្តីត្រូវការជាមូលដ្ឋាននានារបស់ខ្លួន។

ឯកសារជំនួយស្មារតីនេះ មានគោលដៅផ្តល់ជាតុចូលបន្ថែមតាមរយៈឧបករណ៍សំខាន់ៗមួយចំនួនដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាជិក គ.ផ.ថ. ប្រើប្រាស់សម្រាប់ធ្វើការពិភាក្សាជាមួយក្រុមជនងាយរងគ្រោះក្នុងសហគមន៍អំពីបញ្ហានានារបស់ពួកគាត់ ដែលកើតចេញពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងស្វែងរកដំណោះស្រាយនានាដែលមានលក្ខណៈសមស្របនៅថ្នាក់ភូមិ មុនពេលចាប់ផ្តើម ឬក្នុងអំឡុងកិច្ចដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

## ៥. គោលការណ៍

### ៥.១. គោលការណ៍សម្រាប់ការកសាងផែនការឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាអង្គនយោបាយដែលកើតចេញពីការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ។ ដូច្នេះ ក្រុមប្រឹក្សាឃុំត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋអំពីការធ្វើសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ខ្លួន ពិសេសពាក់ព័ន្ធនឹងការរៀបចំផែនការ និងការប្រើប្រាស់មូលនិធិឃុំ សង្កាត់។ ជាមួយគ្នានេះដែរ ក្នុងកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំ

រំកិលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាថា កិច្ចដំណើរការនេះត្រូវបានអនុវត្តប្រកបដោយតម្លាភាព មានគណនេយ្យភាព និងមានសមធម៌ចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ៥.២. គោលការណ៍ សម្រាប់ការបញ្ជ្រាបភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ប្រកបដោយបរិយាប័ន្នសង្គមក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

ផ្អែកលើសេចក្តីណែនាំនានាដែលបានរៀបចំ ការបញ្ជ្រាបនូវការប្រែប្រួលអាកាសធាតុ ប្រកបដោយបរិយាប័ន្នសង្គមទៅក្នុងកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ត្រូវធានាឲ្យមាន ៖

- ការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ពិសេសក្រុម ឬជនងាយរងគ្រោះ ដែលតាមរយៈការចូលរួមនេះ មតិយោបល់ និងតម្រូវការនានារបស់ពួកគាត់ ត្រូវបានយកមកពិចារណា និងដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសថ្នាក់ឃុំ សង្កាត់។
- ការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម ៖ តាមរយៈការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមនៃការបន្សុំនឹងការប្រែប្រួលអាកាសធាតុនៅក្នុងកិច្ចដំណើការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់នឹងរួមចំណែកក្នុងការលើកកម្ពស់កិច្ចអភិវឌ្ឍ ប្រកបដោយនិរន្តរភាព។



- វិធីសាស្ត្រនៃការបញ្ជ្រាបត្រូវមានលក្ខណៈសាមញ្ញ ងាយយល់ មានភាពងាយស្រួលក្នុងការអនុវត្ត និងចំណាយថវិកាតិច។
- មិនតម្រូវឲ្យកែប្រែសេចក្តីណែនាំនានាដែលមានស្រាប់។

## ៦. សកម្មភាព និងយន្តការបញ្ជ្រាបការប្រែប្រួលអាកាសធាតុប្រកបដោយបរិយាប័ន្នសង្គមក្នុងកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

### ៦.១. សកម្មភាព

ការបញ្ជ្រាបនូវការប្រែប្រួលអាកាសធាតុ ប្រកបដោយបរិយាប័ន្នសង្គមក្នុងកិច្ចដំណើរការរកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ត្រូវអនុវត្តស្របតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។ ផ្អែកតាមសេចក្តីណែនាំនេះ កិច្ចដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ តម្រូវឲ្យមានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ គ.ផ.ថ. ដែលមានតំណាងមកពីភូមិនីមួយៗនៅក្នុងឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានា។ អាស្រ័យហេតុនេះ ដើម្បីធានាថាតម្រូវការជាអាទិភាព និងការវិនិយោគនានារបស់ឃុំ សង្កាត់ បានយកចិត្តទុកដាក់លើបញ្ហានានានៃការប្រែប្រួលអាកាសធាតុ និងការលើកកម្ពស់បរិយាប័ន្ននិងសមធម៌សង្គម គ.ផ.ថ. និងអ្នកពាក់ព័ន្ធនានាត្រូវយកចិត្តទុកដាក់ជាពិសេសលើការវិភាគស្ថានភាព ក្នុងជំហានទី១នៃ

ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល តាមរយៈការអនុវត្តសកម្មភាពបន្ថែមចំនួន ៤ គឺ ៖

- ការវិភាគ និងការកំណត់អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅថ្នាក់ភូមិ
- ការកំណត់ និងការវិភាគអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ មកលើក្រុមគោលដៅជាក់លាក់នៅថ្នាក់ភូមិ
- ការរៀបចំប្រតិទិនរដូវកាល
- ការកំណត់បញ្ហា តម្រូវការ និងដំណោះស្រាយ។

## ៦.២. យន្តការ

នៅថ្នាក់ឃុំ សង្កាត់ គ.ផ.ថ. គឺជាអ្នកទទួលខុសត្រូវដ៏សំខាន់ក្នុងការអនុវត្តសកម្មភាពទាំង៤ដែលបានរៀបរាប់ខាងលើ។ ពាក់ព័ន្ធបញ្ហានេះ គ.ផ.ថ. មួយចំនួនអាចមិនទាន់មានចំណេះដឹង និងជំនាញសមស្រប ដើម្បីអនុវត្តកិច្ចការនេះប្រកបដោយប្រសិទ្ធភាព។ អាស្រ័យហេតុនេះ យន្តការសម្រាប់ការអនុវត្តសកម្មភាពទាំងនេះ គួរបែងចែកជា២ផ្នែកដូចខាងក្រោម ៖

**ក). យន្តការអនុវត្តផ្ទាល់** គឺ គ.ផ.ថ. ត្រូវអនុវត្តកិច្ចការចម្បងចំនួនពីរបន្ថែមលើការងារ ដែលត្រូវអនុវត្តនៅក្នុងជំហានទី១នៃកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់គឺ ៖

- <u>ទី១</u> ៖ ការវិភាគ និងការកំណត់អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅតាមភូមិ និងនៅថ្នាក់ឃុំ សង្កាត់ តាមរយៈ ការរៀបចំផែនទីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដោយមានការចូលរួម។ កិច្ចការនេះមិនទាមទារកម្រិតជំនាញខ្ពស់ឡើយ ប៉ុន្តែតម្រូវឲ្យមានការយល់ដឹងច្បាស់លាស់អំពីទីតាំង និងធនធាននានាដែលមាននៅក្នុងមូលដ្ឋានរបស់ខ្លួន។ ជាក់ស្តែង ឃុំ សង្កាត់នីមួយៗបានបង្កើត គ.ផ.ថ. ដែលមានមេភូមិ ឬអ្នកតំណាងផ្សេងទៀតអាចមានចំណេះដឹងអំពីបញ្ហានេះ។ ជាមួយគ្នានេះដែរ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិ ក្រុមយុវជន គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ មន្ត្រីបង្គោល និងគណៈកម្មការនានាដែលស្ថិតនៅក្រោមក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ជាអ្នកដែលអាចដឹងអំពីបញ្ហានៃការប្រែប្រួលអាកាសធាតុ ក្នុងងមូលដ្ឋានរបស់ខ្លួន និងអាចចូលរួមក្នុងការអនុវត្តសកម្មភាពទី១នេះផងដែរ។ ដូច្នេះ គ.ផ.ថ. ត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួល និងការអនុវត្តសកម្មភាពទី១នេះ។
- <u>ទី២</u> ៖ ការវិភាគ និងការកំណត់អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើក្រុមជាក់លាក់នានានៅតាមភូមិ និងនៅថ្នាក់ឃុំ សង្កាត់។ គ.ក.ន.ក. ត្រូវចូលរួមក្នុងការអនុវត្តកិច្ចការនេះ ព្រោះសមាជិក គ.ក.ន.ក. បានចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តការងារសេវាសង្គមនៅថ្នាក់ភូមិ និងមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកផ្តល់សេវាសង្គមនានា។ ដូច្នេះ គ.ផ.ថ. និង គ.ក.ន.ក. គឺជាយន្តការដ៏សំខាន់ក្នុងការអនុវត្តសកម្មភាពទី២នេះ។

ខ). យន្តការគាំទ្រសមត្ថភាព

ក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ទៅក្នុងកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ក្រុមប្រឹក្សាឃុំ សង្កាត់អាចស្វែងរកការគាំទ្រផ្នែកសមត្ថភាពពីស្ថាប័ន អង្គភាពសំខាន់ៗមួយចំនួនមានដូចជា ៖

- **រដ្ឋបាលក្រុង ស្រុក ៖** ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ដែលជាយន្តការមួយមានអាណត្តិការងារក្នុងការគាំទ្រដល់ឃុំ សង្កាត់ ពិសេសការគាំទ្រផ្នែកសមត្ថភាព។
- **ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យាក្រុង ស្រុក ៖** ក្រុមប្រឹក្សាឃុំ សង្កាត់អាចទំនាក់ទំនង និងស្នើសុំការគាំទ្រពីរដ្ឋបាលក្រុង ស្រុកចាត់បញ្ជូនទីប្រឹក្សា ឬបុគ្គលិកកិច្ចសន្យាក្រុង ស្រុក ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួន។ ជាមួយគ្នានេះដែរ ទីប្រឹក្សា ឬបុគ្គលិកកិច្ចសន្យាក្រុង ស្រុកក៏អាចផ្តល់ការគាំទ្រ ឬជួយកៀរគរធនធានពីខាងក្រៅ ឬពីអង្គភាពជំនាញនានានៅថ្នាក់ខេត្ត ឬពីអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីគាំទ្រការអភិវឌ្ឍសមត្ថភាពរបស់ឃុំ សង្កាត់។
- **មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត ៖** ក្រុមប្រឹក្សាឃុំ សង្កាត់ អាចទំនាក់ទំនងជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តដោយផ្ទាល់ ដើម្បីសុំការគាំទ្រផ្នែកអភិវឌ្ឍន៍សមត្ថភាព។ មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សអាចកៀរគរការគាំទ្រពីមន្ទីរ អង្គភាពនានាមានដូចជា ទីចាត់ការផែនការនិងវិនិយោគ មន្ទីរផែនការ មន្ទីរបរិស្ថាន មន្ទីរកសិកម្ម មន្ទីរកិច្ចការនារីជាដើម ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធផងដែរ។



- **ក្រសួង ស្ថាប័ន ៖** តាមរយៈយន្តការនៅថ្នាក់ខេត្ត និងក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់អាចទទួលការបណ្តុះបណ្តាលដោយផ្ទាល់ពីក្រសួង ស្ថាប័ននានាដូចជា លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូច្នេះ ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវការបំប៉នសមត្ថភាពក្នុងការដាក់បញ្ចូលនូវការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ននិងសមធម៌សង្គមក្នុងកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ត្រូវរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួន ដោយសហការជាមួយការិយាល័យផែនការនិងគាំទ្រឃុំ សង្កាត់ និងការិយាល័យពាក់ព័ន្ធនៅថ្នាក់ក្រុង ស្រុក ដើម្បីកំណត់ប្រធានបទអភិវឌ្ឍន៍សមត្ថភាព និងអ្នកផ្តល់ការគាំទ្រ។
- **អង្គការមិនមែនរដ្ឋាភិបាល ៖** អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ការងារយេនឌ័រ បរិយាប័ន្ននិងសមធម៌សង្គម គឺជាយន្តការដែលនៅកៀកជិត និងងាយស្រួលទំនាក់ទំនង និងស្នើសុំសេវាគាំទ្រនានា។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនអាចផ្តល់ការអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធនានានៅថ្នាក់ឃុំ សង្កាត់តាមរយៈការបណ្តុះបណ្តាល

ឬតាមរយៈការចូលរួមធ្វើការជាមួយគ្នា។ ក្រៅពីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏អាចទទួលបាននូវការគាំទ្រផ្នែកថវិកាពីអង្គការមួយចំនួនទៀតដែលមានទីតាំងនៅក្រៅឃុំ សង្កាត់ សម្រាប់ការបណ្តុះបណ្តាលមន្ត្រីបង្គោលរបស់ខ្លួន។

## ៧. យុទ្ធសាស្ត្រអនុវត្ត

ដូចបានបញ្ជាក់ខាងលើ ការដាក់បញ្ចូលបញ្ហានៃការប្រែប្រួលកាសធាតុ ប្រកបដោយបរិយាប័ន្នសង្គមទៅក្នុងកិច្ចដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ត្រូវអនុវត្តស្របតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។ ដូច្នេះ ការអនុវត្តសកម្មភាពទាំង៤ខាងលើ ត្រូវធ្វើឡើងស្របតាមកិច្ចដំណើរការ និងជំហាននានានៃការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។ ក្នុងន័យនេះ គ.ផ.ថ. និង គ.ក.ន.ក. ដែលជាអ្នកទទួលខុសត្រូវសំខាន់ ត្រូវអនុវត្តសកម្មភាពទាំង៤នេះ ដូចមានបរិយាយលម្អិតខាងក្រោម ៖

### ៧.១. ការវិភាគ និងការកំណត់ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅតាមភូមិ

នៅក្នុងជំហានទី១នៃកិច្ចដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ គ.ផ.ថ. ត្រូវវិភាគ និងកំណត់ស្ថានភាព និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ



តាមភូមិនីមួយៗឲ្យបានច្បាស់លាស់ ដោយមានការគាំទ្រពីការិយាល័យផែនការ និងគាំទ្រឃុំសង្កាត់។

ចំពោះឃុំ សង្កាត់ណា ដែលចេះប្រើប្រាស់ឧបករណ៍នៃការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ (Vulberability Reduction Assessment - VRA វី.អ.អេ) សម្រាប់ការវិភាគ និងការកំណត់អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ឃុំ សង្កាត់នោះត្រូវប្រើប្រាស់ឧបករណ៍នេះសម្រាប់ការវិភាគ និងការកំណត់អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងឃុំ សង្កាត់របស់ខ្លួន ស្របតាមកិច្ចដំណើរការ ជំហាន និងនីតិវិធីដែលបានកំណត់។ ដោយឡែកឃុំ សង្កាត់ណាដែលមិនទាន់ចេះប្រើប្រាស់ឧបករណ៍ VRA ត្រូវធ្វើការវិភាគផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងឃុំ សង្កាត់របស់ខ្លួន ដោយអនុវត្តតាមសកម្មភាពសំខាន់ៗដូចខាងក្រោម ៖

- គូសផែនទីឃុំ សង្កាត់នៅលើក្រដាសផ្ទាំងធំដោយកំណត់អំពីទីតាំងនៃធនធានធម្មជាតិនានា ដែលមាននៅក្នុងឃុំ សង្កាត់ដូចជា ព្រៃឈើ តំបន់បេតិកភ័ណ្ឌ បឹងបួរ ទន្លេ សមុទ្រ។ល។ តាមពិត ផែនទីនេះបាន និងកំពុងប្រើប្រាស់ក្នុងកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។
- កំណត់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដូចជា ផ្លូវ ប្រព័ន្ធធារាសាស្ត្រ សាលារៀន មណ្ឌលសុខភាព និងទីតាំងអគារសាធារណៈផ្សេងៗទៀត ដែលអាចមើលឃើញនៅលើផែនទី។

- ពិភាក្សាជាមួយអ្នកចូលរួមនៅថ្នាក់ភូមិ ដោយបង្ហាញពីផែនទីឃុំ សង្កាត់ដែលបានរៀបចំ ដើម្បីងាយស្រួលក្នុងការកំណត់ទីតាំងភូមិ និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដូចជា ផ្លូវ ប្រព័ន្ធធារាសាស្ត្រ ស្ទឹង បឹងបួរ សាលារៀនមណ្ឌលសុខភាព និងទីតាំងអគារសាធារណៈផ្សេងៗទៀតក្នុងឃុំ និងភូមិរបស់ខ្លួន។ ការគូសផែនទីភូមិជាមួយអ្នកភូមិមានគោលដៅលើកកម្ពស់ការយល់ដឹង និងធ្វើការវិភាគរួមគ្នាអំពីផលប៉ះពាល់នានានៃការប្រែប្រួលអាកាសធាតុដូចជាទឹកជំនន់ គ្រោះរាំងស្ងួត ការផ្ទុះឡើងនូវសត្វល្អិតចង្រៃបំផ្លាញដំណាំ ខ្យល់ព្យុះ ជាដើម។
- ពិនិត្យមើលឡើងវិញជាមួយអ្នកភូមិ អំពីកម្រិតនៃផលប៉ះពាល់ដែលបានកំណត់ ដូចមានឧទាហរណ៍នៅលើផែនទីទាំងនេះដូចខាងក្រោម ៖

**គំរូផែនទីឃុំ**





**គំរូផែនទីភូមិ**



(ការរៀបចំផែនទីលម្អិតមាននៅក្នុងឧបសម្ព័ន្ធទី១)

ការគូសផែនទីខាងលើ អាចជួយអ្នករៀបចំផែនការយល់ដឹងអំពីតំបន់ងាយរងគ្រោះនានា ដែលទទួលផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដូចជា គ្រោះរាំងស្ងួត ឬទឹកជំនន់ជាដើម។

ដើម្បីវិភាគពីនិន្នាការ និងផលប៉ះពាល់ ព្រមទាំងគម្រោងសកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ គ.ផ.ថ. ត្រូវយល់ដឹង និងចេះប្រើប្រាស់ឧបករណ៍នានាដូចជា VRA និងឧបករណ៍ទម្រង់អក្សរ H "អេច" ជាដើម។ ក្នុងករណី គ.ផ.ថ. មិនទាន់យល់ដឹងនិងចេះប្រើប្រាស់ឧបករណ៍ សម្រាប់ការវិភាគអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនានា គ.ផ.ថ. គួរធ្វើការវិភាគដោយអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម ៖

- ពិនិត្យ និងជ្រើសរើសប្រភេទនៃផលប៉ះពាល់ដែលកើតមានឡើងនៅក្នុងភូមិរបស់ខ្លួន (ដែលបានកំណត់នៅពេលគូសផែនទីឃុំ សង្កាត់ និងភូមិ) ហើយស្រង់យកប្រភេទនៃផលប៉ះពាល់ទាំងនោះចូលក្នុងកូឡោនទី១នៃតារាងម៉ាទ្រិចតាមកម្រិតនៃផលប៉ះពាល់(ផលប៉ះពាល់ខ្លាំងនៅលើគេ)។
- ដាក់ពិន្ទុពី ១ ដល់ ៥ (គូសរង្វង់) ផ្អែកតាមកម្រិតនៃផលប៉ះពាល់ និងការចងចាំរបស់អ្នកចូលរួមអំពីស្ថានភាពនៃផលប៉ះពាល់នានា ដែលធ្លាប់កើតមានឡើងក្នុងចន្លោះពេលពី ១០ ឆ្នាំទៅ ២០ ឆ្នាំកន្លងមក។ ពិន្ទុ ១ គឺកម្រិតប៉ះពាល់តិចតួច ហើយ ៥ គឺប៉ះពាល់ខ្លាំង ឬធ្ងន់ធ្ងរ។

**ទម្រង់វិភាគនិន្នាការ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ**

| ប្រភេទ | ឆ្នាំទទួលផលប៉ះពាល់ | | | | សម្គាល់ |
|---|---|---|---|---|---|
| | 1993-1998 | 1999-2004 | 2005-2009 | 2010-2015 | |
| រលកកំដៅ | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | |
| រាំងស្ងួត | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | |
| ទឹកជំនន់ | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | |
| សត្វល្អិត | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | |
| ជំងឺ | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | |

<u>សម្គាល់ ៖</u>

- គ.ផ.ថ. ឬអ្នកសម្របសម្រួល ត្រូវរកកន្លែងធំទូលាយ និងសមស្រប ដើម្បីប្រជុំពិភាក្សា និងដាក់ផែនទីដែលបានគូស និងតារាងម៉ាទ្រិចដែលបានរៀបចំខាងលើ ក៏ដូចជាឲ្យអ្នកចូលរួមងាយស្រួលពិនិត្យមើលផែនទី និងទម្រង់និន្នាការក្នុងពេលជាមួយគ្នា។ ការធ្វើបែបនេះ ក៏អាចជួយឱ្យអ្នកចូលរួមរំលឹក ឬនឹកឃើញអំពីស្ថានភាពនៃគ្រោះធម្មជាតិដែលធ្លាប់កើតមានឡើងក្នុងឃុំ សង្កាត់ និងភូមិរបស់ខ្លួន។ បន្ទាប់មកអ្នកសម្របសម្រួល ត្រូវកត់សម្គាល់ទីតាំងជាក់លាក់នៃផលប៉ះពាល់នានានៅលើផែនទី។



- ក្នុងការអនុវត្តកិច្ចការនេះ មានឯកសារ និងធនធានសមស្របជាច្រើននៅថ្នាក់ក្រុង ស្រុក ថ្នាក់ខេត្ត និងនៅថ្នាក់ជាតិ សម្រាប់ជាចំណេះដឹង និងជួយក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់ជាឯកសារយោងដូចជា សៀវភៅណែនាំស្តីពី "**អនុវត្តការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ**" ឬ VRA ដែលបានបោះពុម្ពដោយ UNDP ក្នុងឆ្នាំ២០១៥។

តាមរយៈការអនុវត្តឧបករណ៍នេះ គ.ផ.ថ. និងអ្នកចូលរួមអាចកំណត់បានថា តើផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុប្រភេទណាដែលបានកើតឡើង និងបង្កផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ និងញឹកញាប់ជាងគេ ហើយនៅកន្លែងណា។

### ៧.២. ការវិភាគ និងការកំណត់ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើក្រុមគោលដៅជាក់លាក់

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលបានដាក់ឲ្យអនុវត្តនៅឆ្នាំ ២០០១ តម្រូវឲ្យក្រុមប្រឹក្សាឃុំ សង្កាត់រៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ។ លើសពីនេះទៀត ក្នុងនាមជាអង្គដែលកើតចេញពីការ

បោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តសកម្មភាពនានា ដើម្បីផ្តល់សេវានានាជូនប្រជាពលរដ្ឋ ដោយថ្លឹងថ្លែងអំពីធនធានដែលខ្លួនមាន និងតម្រូវការនានារបស់ប្រជាពលរដ្ឋ។

ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសគម្រោងវិនិយោគ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដែលបានផ្តល់ផលប៉ះពាល់ដល់សហគមន៍ទាំងមូល និងជាពិសេសប៉ះពាល់ដល់ជនក្រីក្រ និងជនងាយរងគ្រោះនានា។

ក្នុងការចាត់អាទិភាព ដើម្បីឆ្លើយតបទៅនឹងបញ្ហានៃការប្រែប្រួលអាកាសធាតុដែលមានវិសាលភាពធំធេង គ.ផ.ថ. គួរប្រើប្រាស់ផែនទីចំនួន២រួមគ្នាសម្រាប់ជាជំនួយ គឺផែនទីនៃការប្រែប្រួលអាកាសធាតុដែលខ្លួនបានរៀបចំ និងផែនទីសេវាសង្គម( ឧបសម្ព័ន្ធទី២ )ដែលបង្ហាញអំពីតម្រូវការនានាផ្នែកសេវានានាក្នុងភូមិ និងមានសូចនាករចំនួន១៧។ ផ្អែកលើបទពិសោធន៍នៃការសាកល្បង និងក្នុងករណីឃុំមិនមានផែនទីសេវាសង្គម គ.ផ.ថ. និងអ្នកសម្របសម្រួលអាចជ្រើសរើសយកសូចនាករសំខាន់ៗមួយចំនួនដូចជា សូចនាករពាក់ព័ន្ធនឹងចំនួនស្ត្រីមេម៉ាយ ចំនួនស្ត្រីដែលមិនធ្លាប់សម្រាលកូននៅមន្ទីរពេទ្យ ចំនួនកុមារអាយុពី៩ទៅ១២ខែដែលមិនធ្លាប់បានទទួលថ្នាំបង្ការ ចំនួនកុមារមិនបានចូលសិក្សា។ល។

តាមរយៈការពិនិត្យមើល និងការប្រៀបធៀបផែនទីនៃការប្រែប្រួលអាកាសធាតុ និន្នាការនិងផលប៉ះពាល់ដែលបានវិភាគ និងផែនទីសេវាសង្គម ឬចំនួននៃក្រុមជនងាយរងគ្រោះក្នុងភូមិខាងលើ គ.ផ.ថ.



អាចកំណត់បាននូវតំបន់ ដែលទទួលផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរ និងញឹកញាប់ជាងគេ និងសេវាមួយចំនួនដែលជាតម្រូវការខ្ពស់ និងចាំបាច់សម្រាប់ក្រុមជនងាយរងគ្រោះ ដែលទទួលផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

### ៧.៣. ការរៀបចំប្រតិទិនរដូវកាល

គ.ផ.ថ. ត្រូវរៀបចំប្រតិទិនរដូវកាល ដើម្បីកំណត់ និងបែងចែកសកម្មភាពនានាតាមរដូវកាលសម្រាប់ក្រុម ឬជនងាយរងគ្រោះនានាដែលទទួលផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

គ.ផ.ថ. ដែលបានរៀបចំរួចរាល់នូវផែនទីនៃការប្រែប្រួលអាកាសធាតុ និងផែនទីសេវាសង្គម អាចដឹងច្បាស់លាស់អំពីទីកន្លែងដែលទទួលរងផលប៉ះពាល់ផ្សេងៗពីការប្រែប្រួលអាកាសធាតុ និងក្រុមឬជនងាយរងគ្រោះនៅក្នុងតំបន់ ឬកន្លែងនោះ។

ដូច្នេះ ការរៀបចំប្រតិទិនតាមរដូវកាលនឹងជួយ គ.ផ.ថ. ក្នុងការកំណត់ពេលវេលា ដែលអាចកើតមានឡើងនូវផលប៉ះពាល់នានា (ដូចជា រយៈពេលអូសបន្លាយនៃរដូវរាំងស្ងួត រលកកំដៅ ឬទឹកជំនន់) និងសកម្មភាពរបស់ប្រជាពលរដ្ឋ ដើម្បីសម្របតាមស្ថានភាពនៃគ្រោះដែលកើតឡើងទាំងនោះដូចជា ពេលវេលាសម្រាប់ជម្លៀសប្រជាពលរដ្ឋទៅរកកន្លែងសុវត្ថិភាព និងការកើតឡើងនូវប្រភេទជំងឺតាមរដូវកាល ឬពេលវេលាដែលស្ត្រី ឬកុមារពាក់ព័ន្ធនឹងសកម្មភាពរកចំណូលក្នុងភូមិ ឬក្រៅភូមិដែលជាមូលហេតុធ្វើឱ្យពួកគាត់មិនអាចមកទទួលសេវា ឬផលប្រយោជន៍នានាពីគម្រោងអភិវឌ្ឍន៍។

(វិធីសាស្ត្រ សម្រាប់ការរៀបចំប្រតិទិនតាមរដូវកាលស្តីពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមាននៅក្នុងឧបសម្ព័ន្ធទី៣)។

### ៧.៤. ការកំណត់បញ្ហា តម្រូវការ និងដំណោះស្រាយ

ក្នុងកិច្ចដំណើរការកសាងអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ការកំណត់បញ្ហា តម្រូវការ និងដំណោះស្រាយ គឺធ្វើឡើងក្នុងជំហានទី១។ ដូច្នេះ លទ្ធផលនៃការវិភាគ និងការកំណត់ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការកំណត់អាទិភាពនៃការវិភាគផលប៉ះពាល់លើក្រុមគោលដៅនិងតាមភូមិជាក់លាក់ ត្រូវស្រង់ចូលក្នុងទម្រង់អាទិភាពបឋមនៃភាពស៊ាំ ទៅនឹងការប្រែប្រួលអាកាសធាតុ ដូចមានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម ៖

តារាងអាទិភាពបឋមនៃភាពបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ

| ល.រ | គ្រោះធម្មជាតិ | បញ្ហា | ទីតាំង | ដំណោះស្រាយ | សម្គាល់ |
|---|---|---|---|---|---|
| ១ | រលកកំដៅ | - កុមារកើតជំងឺរាគ និងក្អួត | ចុងភូមិ ក | - បង្កើនការចុះអប់រំ និងផ្សព្វផ្សាយរបស់មណ្ឌលសុខភាព ឬក្រុមទ្រទ្រង់សុខភាពភូមិ (VHSG)<br>- បង្កើតមណ្ឌលសុខភាពនៅក្បែរភូមិ | - ករណីនេះកើតឡើងពីរឆ្នាំជាប់គ្នា ២០១៤ និង២០១៦ |
| ២ | ភាពរាំងស្ងួតអូសបន្លាយរយៈពេលយូរ (ពីខែមករា ដល់ខែមិថុនា) | - ខ្វះទឹកប្រើប្រាស់ | ទូទាំងភូមិ ក | - ស្តារស្រះក្នុងវត្ត...<br>- ផ្តល់អណ្តូងជម្រៅលើសពី៣០មដល់គ្រួសារក្រីក្រ | - (អាចបញ្ជាក់ឈ្មោះគ្រួសារ) |



ដើម្បីធានាថា លទ្ធផលនៃការវិភាគប្រកបដោយបរិយាប័ន្នសង្គមអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ គ.ផ.ថ. ត្រូវអនុវត្តតាមសកម្មភាពនានាដូចខាងក្រោម ៖

- ស្រង់ផលប៉ះពាល់នានា ដែលទទួលបានចំណាត់ថ្នាក់ឬពិន្ទុខ្ពស់ ឧ. ពិន្ទុពី ៣-៥ (ស្រង់ពីទម្រង់សម្រាប់វិភាគនិន្នាការ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ)
- ពិភាក្សាអំពីស្ថានភាពនៃផលប៉ះពាល់នានា ជាមួយប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ និងសេវាសង្គមនានា ព្រមទាំងធ្វើការកំណត់បញ្ហា និងតម្រូវការនានារបស់ប្រជាពលរដ្ឋជាមួយក្រុមងាយរងគ្រោះដោយផ្ទាល់
- ពិភាក្សា និងកំណត់ដំណោះស្រាយដែលសមស្របទៅនឹងស្ថានភាពជាក់ស្តែង និងលទ្ធភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- កត់ត្រាលទ្ធផលពិភាក្សាក្នុងទម្រង់ខាងលើ។

**<u>កំណត់សម្គាល់ ៖</u>**

✓ សកម្មភាពដែលបានរៀបរាប់ក្នុងចំណុច ៧.១. ដល់៧.៤ គឺជា កិច្ចដំណើរការនៃការឆ្លុះបញ្ចាំងអំពីការអភិវឌ្ឍនៅក្នុងសហគមន៍។ ដូច្នេះ ក្រុមប្រឹក្សាឃុំ និង គ.ផ.ថ. អាចកំណត់នូវព្រឹត្តិការណ៍ផ្សេងទៀត សម្រាប់រយៈពេលពេញ

មួយឆ្នាំដូចជា ពិធីបុណ្យប្រពៃណី ព្រឹត្តិការណ៍វប្បធម៌ និងសាសនា និងសកម្មភាពនានា ក្រៅពីសកម្មភាពនៃកិច្ចដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ដូចជា ការវិភាគស្ថានភាព និងការពិភាក្សានានាជាដើម។

✓ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចដំណើរការកំណត់អំពីបញ្ហា តម្រូវការ និងដំណោះស្រាយ គ.ផ.ថ. ត្រូវបង្កលក្ខណៈឱ្យមានក្រុមពិភាក្សា ដោយបែងចែងអ្នកចូលរួមតាមភេទ តាមអាយុ ឬតាមប្រធានបទ។ល។ ឧទាហរណ៍ការពិភាក្សាអំពីរលកកំដៅ ដែលជាបញ្ហាដ៏អាក្រក់បំផុតនាប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រុមបុរស ស្ត្រី ស្ត្រីមានកូនអាយុក្រោម៥ឆ្នាំ យុវជន គួរអនុញ្ញាតឱ្យប្រជុំដោយឡែករយៈពេល១០-១៥នាទី ដើម្បីកំណត់ និងស្នើសុំអាទិភាពចំនួន១-៣ សម្រាប់កូនរបស់ខ្លួន ឬសម្រាប់ដោះស្រាយបញ្ហាខ្លួនឯងផ្ទាល់។

គ.ផ.ថ. គួរអនុវត្តសកម្មភាពនានាមួយចំនួនទៀត ដូចជាការជូនដំណឹងអំពីកម្មវិធីប្រជុំតាមភូមិជាមុន តាមរយៈអាជ្ញាធរភូមិ មន្ត្រីបង្គោលនារីកុមារឃុំ គណៈកម្មការវត្ត គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិ សាលារៀន មណ្ឌលសុខភាព ក្រុមស្ត្រី ក្រុមកុមារ ក្រុមយុវជន អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត។ ក្នុងករណីនៅតែមិនមានអ្នកចូលរួម គ.ផ.ថ. អាចរៀបចំកិច្ចប្រជុំក្រុមតូចៗនៅតាមកន្លែង និងពេលវេលាផ្សេងនៅតាមភូមិនីមួយៗ ដូចជា



នៅតាមតំបន់ខ្ពង់រាប គួររៀបចំកិច្ចប្រជុំភូមិនៅពេលយប់ ដែលអាចមានអ្នកចូលរួមបានច្រើនជាងពេលថ្ងៃ។

## ៨. កិច្ចដំណើរការអនុវត្ត

ដើម្បីធានាថា គម្រោងអាទិភាពពាក់ព័ន្ធនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ បញ្ហាយេនឌ័រ បរិយាប័ន្ននិងសមធម៌សង្គម ត្រូវបានយកចិត្តទុកដាក់ និងទទួលបានការគាំទ្រថវិកា ក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ផ.ថ. ត្រូវអនុវត្តសកម្មភាពបន្ថែមមួយចំនួន ស្របតាមជំហានដូចខាងក្រោម ៖

### ក). ការចាត់អាទិភាពគម្រោង

(ជំហានទី១នៃការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់)

បន្ទាប់ពីកិច្ចប្រជុំ និងពិភាក្សាជាមួយប្រជាពលរដ្ឋ (ជំហានទី១) គ.ផ.ថ. អាចកំណត់បាននូវបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ និងដំណោះស្រាយសមស្របនានា។ ផ្អែកតាមលទ្ធផលនេះ នៅពេលប្រជុំនៅថ្នាក់ឃុំ សង្កាត់ គ.ផ.ថ. ត្រូវពិនិត្យ និងកំណត់អំពីបញ្ហា និងតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋ។ ដើម្បីធានាថា បញ្ហា និងតម្រូវការនានាពាក់ព័ន្ធនឹងការបន្សាំ ទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានពិចារណា និងយកចិត្តទុកដាក់ប្រកបដោយបរិយាប័ន្នសង្គម និងដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ គ.ផ.ថ. ត្រូវចាត់អាទិភាពបញ្ហាប្រឈមទាំងនេះ ផ្អែកលើការពាក់ព័ន្ធជាមួយនឹង "**ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ**" ដែលជាលក្ខណៈវិនិច្ឆ័យចម្បងមួយ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យសំខាន់ៗ

ផ្សេងទៀតដែលត្រូវប្រើប្រាស់។

បន្ទាប់មក គ.ផ.ថ. ត្រូវបំប្លែងបញ្ហាប្រឈម និងដំណោះស្រាយទាំងនេះទៅជាគម្រោងវិនិយោគ ហើយត្រូវស្រង់ចូលក្នុងតារាង ១.១.ក. ស្តីពីតម្រូវការគម្រោង និងសកម្មភាពអាទិភាពក្នុងជំហានទី១ នៃការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**ខ). ការជ្រើសរើសគម្រោងសម្រាប់ការប្រើប្រាស់មូលនិធិឃុំ សង្កាត់**

(ជំហានទី២នៃការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់)

នៅក្នុងជំហានទី២ បន្ទាប់ពីទទួលបានព័ត៌មានស្តីពីលទ្ធភាពថវិកាសម្រាប់រដ្ឋបាលឃុំ សង្កាត់នីមួយៗ គ.ផ.ថ. ត្រូវរៀបចំ និងធ្វើសុពលភាពគម្រោងឡើងវិញ។ បន្ទាប់មក គ.ផ.ថ. ត្រូវពិភាក្សា និងសម្រេចជ្រើសរើសគម្រោងជាបណ្តោះអាសន្ន ដើម្បីប្រើប្រាស់មូលនិធិឃុំ សង្កាត់ដែលមាន។ ក្នុងការជ្រើសរើសគម្រោងនេះ គ.ផ.ថ. ត្រូវធ្វើការថ្លឹងថ្លែងអំពីតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋ ជាមួយនឹងលទ្ធភាពថវិកាដែលឃុំ សង្កាត់មាន ដើម្បីធានាថា គម្រោងអាទិភាពនានា ដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុទទួលបានការគាំទ្រថវិកាសម្រាប់អនុវត្ត។

**គ). ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ**

(ជំហានទី២នៃការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់)

ដើម្បីលើកកម្ពស់គណនេយ្យភាព និងមានការចូលរួមរបស់ប្រជាពលរដ្ឋ មេភូមិនីមួយៗដែលជាសមាជិក គ.ផ.ថ. ត្រូវស្រង់យកសេចក្តីព្រាងបញ្ជីគម្រោងដែលគ្រោងនឹងប្រើប្រាស់មូលនិធិឃុំ រួមទាំងគម្រោង ដែលឆ្លើយតបនឹងការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុទៅ



ជួបពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន។ ផ្អែកតាមមតិយោបល់របស់ប្រជាពលរដ្ឋ គ.ផ.ថ. ត្រូវពិចារណា និងកែសម្រួលជាចុងក្រោយ ដើម្បីដាក់ជូនមេឃុំ ចៅសង្កាត់ពិនិត្យ និងឯកភាពមុននឹងដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងសម្រេច។

**ឃ). ការផ្សព្វផ្សាយអំពីគម្រោង**

(ជំហានទី៣នៃការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់)

ក្នុងជំហានទី៣ បន្ទាប់ពីការអនុម័តដាក់ឲ្យអនុវត្តនូវកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុកត្រូវធ្វើការណែនាំអភិបាលខេត្ត អភិបាលក្រុង អភិបាលស្រុករបស់ខ្លួនរៀបចំបញ្ជីគម្រោង ដែលត្រូវអនុវត្តក្នុងដែនដីរដ្ឋបាលនៃឃុំ សង្កាត់នីមួយៗ និងធ្វើជូនមេឃុំ ចៅសង្កាត់ពាក់ព័ន្ធ ដើម្បីឲ្យមេឃុំ ចៅសង្កាត់ទាំងនោះយកព័ត៌មានអំពីគម្រោងទាំងនេះ រួមបញ្ចូលជាមួយនឹងគម្រោងនានារបស់ឃុំ សង្កាត់ ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនប្រជាពលរដ្ឋរបស់ខ្លួន។

**ឧបសម្ព័ន្ធទី១**

## ឧបករណ៍
## វិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

ការបញ្ជ្រាបភាពស៊ាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនានានៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ត្រូវផ្អែកជាមូលដ្ឋានលើសេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។ ដូច្នេះកិច្ចដំណើរនៃការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ត្រូវអនុវត្តចាប់តាំងពីដំហានដំបូងនៃការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

អាស្រ័យហេតុនេះ ក្នុងការបញ្ជ្រាបភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យ គ.ផ.ថ. និងអ្នកពាក់ព័ន្ធនានាត្រូវប្រើប្រាស់ឧបករណ៍នានាដូចខាងក្រោម ៖

### ១). ឧបករណ៍ទី១ ៖ ការគូសផែនទីហានិភ័យនៃការប្រែប្រួលអាកាសធាតុ

ការរៀបចំផែនទីនេះ នឹងជួយកំណត់ពីមុខសញ្ញាហានិភ័យនៃការប្រែប្រួលអាកាសធាតុ ដែលបានកើតឡើងក្នុងមូលដ្ឋាន។ ការគូសផែនទីនឹងជួយអ្នករៀបចំផែនការក្នុងការកំណត់ទីតាំង និងស្ថានភាពនៃភាពងាយរងគ្រោះ ដើម្បីឈានទៅធ្វើការវិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ការគូសផែនទីនេះ ត្រូវធ្វើឡើងនៅថ្នាក់ឃុំ សង្កាត់ ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សា គ.ក.ន.ក. ប្រធានភូមិ និងអ្នកពាក់ព័ន្ធនានា ដោយយកផែនទីរដ្ឋបាលឃុំ សង្កាត់មកប្រើប្រាស់ធ្វើជាមូលដ្ឋាន។

ការគូសផែនទីមាន ៤ ជំហានដូចខាងក្រោម ៖

- **<u>ជំហានទី១</u> ៖** គូសទ្រង់ទ្រាយរបស់រដ្ឋបាលឃុំ សង្កាត់ ដោយកំណត់ព្រំប្រទល់រដ្ឋបាលភូមិនានាក្នុងឃុំ សង្កាត់។ បន្ទាប់មក អ្នកចូលរួម ត្រូវគូសបន្ថែមនូវទីតាំងធនធានធម្មជាតិនានាដែលមានក្នុងឃុំ សង្កាត់ដូចជា ទន្លេ ស្ទឹង បឹងបួរ ព្រៃ តំបន់អភិរក្សជាដើម។
- **<u>ជំហានទី២</u> ៖** គូសបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនានាដែលមានទៅក្នុងផែនទីដូចជា ៖
  - ផ្លូវថ្នល់
  - អគារ និងសំណង់សាធារណៈនានាដូចជា វត្តអារាម អគាររដ្ឋបាល សាលារៀន មណ្ឌលសុខភាព...)
  - ទំនប់ទឹក អាងស្តុកទឹក ប្រព័ន្ធធារាសាស្ត្រ អណ្ដូងទឹក និងស្រះ
  - ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី (ម៉ាស៊ីនភ្លើង, ថាមពលកកើតឡើងវិញ...)
  - ទីតាំងចាក់សំរាម ប្រព័ន្ធលូ

– បូជនីយដ្ឋាន ជាដើម

- **<u>ជំហានទី៣</u>** ៖ ក្នុងជំហាននេះ អ្នកចូលរួមត្រូវគូសបញ្ជាក់នៅលើផែនទីអំពីទីតាំងនានា ដែលទទួលរងផលប៉ះពាល់ពីគ្រោះធម្មជាតិ ដោយប្រើប្រាស់គំនូសតាងផ្សេងៗគ្នា ឬប្រើប្រាស់ពណ៌ជាសញ្ញា តាមការឯកភាពគ្នាក្នុងក្រុម។ ផលប៉ះពាល់ពីគ្រោះធម្មជាតិមានដូចជា តំបន់ដែលរងផលប៉ះពាល់ពីទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ សត្វល្អិតបំផ្លាញ ជំងឺរាតត្បាត ការឡើងកំដៅ និងតំបន់ឆ្នេរដែលមានរលកធំៗជាដើម។
- **<u>ជំហានទី៤</u>** ៖ អ្នកចូលរួម ត្រូវកំណត់ និងគូសលើផែនទីអំពីទិដ្ឋភាពនៃស្ថានភាពប្រែប្រួលនានា ដោយប្រៀបធៀបពីពេលមុន និងពេលបច្ចុប្បន្ន (ឧទាហរណ៍ ៖ ទំនប់តាមតំបន់ឆ្នេរ ការបាត់បង់ព្រៃ និងដីអភិរក្ស)។ ការប្រែប្រួលទាំងនេះអាចមានមូលហេតុខុសគ្នាៗដូចជា ផលប៉ះពាល់ពីអាកាសធាតុ គ្រោះធម្មជាតិនានា និងការធ្វើសម្រេចចិត្តផ្នែកនយោបាយ សង្គម និងសេដ្ឋកិច្ចជាដើម។ ប៉ុន្តែទោះបីជាមានមូលហេតុខុសគ្នាក៏ដោយ ក៏ការប្រែប្រួលនៃបរិស្ថានធម្មជាតិ អាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការប្រែប្រួលអាកាសធាតុ ឬគ្រោះធម្មជាតិ។

**តាមរយៈឧបករណ៍ទី១នេះ** អ្នកវិភាគអាចកំណត់បាននូវទីតាំងភូមិសាស្ត្រ ប្រភេទគ្រោះធម្មជាតិ ស្ថានភាពនៃការប្រែប្រួល



និងមូលហេតុនានា ដែលនាំឲ្យមានការប្រែប្រួលស្ថានភាពនៃផលប៉ះពាល់ដែលកើតចេញពីការប្រែប្រួលអាកាសធាតុ។ ឧបករណ៍ទី១នេះនឹងត្រូវប្រើប្រាស់ជាមូលដ្ឋានក្នុងការអនុវត្តឧបករណ៍ផ្សេងៗទៀត។

## ២). ឧបករណ៍ទី២ ៖ ការវិភាគនិន្នាការ

ការវិភាគនិន្នាការ គឺជាឧបករណ៍សម្រាប់កំណត់នូវព្រឹត្តិការណ៍សំខាន់ៗ ដែលកើតមានឡើងដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងព្រឹត្តិការណ៍នានានៃគ្រោះធម្មជាតិ។ លទ្ធផលនៃការវិភាគនេះផ្តល់នូវព័ត៌មានអំពីប្រភេទជាក់លាក់នៃផលប៉ះពាល់ និន្នាការភាពញឹកញាប់ដែលកើតមានឡើង និងកម្រិតនៃភាពធ្ងន់ធ្ងរនៃផលប៉ះពាល់នីមួយៗដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

ការអនុវត្តនូវឧបករណ៍វិភាគនិន្នាការនេះ ត្រូវធ្វើឡើងជាមួយប្រជាពលរដ្ឋដែលស្ថិតក្នុងតំបន់រងគ្រោះ (ផ្អែកលើផែនទីការប្រែប្រួលអាកាសធាតុ) ជនងាយរងគ្រោះ ស្ត្រី ចាស់ជរា និងជនក្រីក្រ ដោយបែងចែកជាក្រុមពិភាក្សាតូចៗ (ឧទាហរណ៍ ៣ ឬ៤ក្រុមពិភាក្សា) ដូចជា ក្រុមស្ត្រី ក្រុមបុរស និងក្រុមអាជ្ញាធរ ឬជាច្រើនក្រុម ផ្អែកតាមសមាសភាពអ្នកចូលរួម និងស្ថានភាពជាក់ស្តែង។ ការវិភាគនិន្នាការត្រូវធ្វើឡើងជា ៣ ជំហានដូចខាងក្រោម ៖

- **<u>ជំហានទី១</u>** ៖ ក្នុងជំហាននេះ អ្នកសម្របសម្រួលត្រូវបំផុសគំនិត និងសាកសួរអ្នកចូលរួមទាំងអំពីព្រឹត្តិការណ៍សំខាន់ៗនៃគ្រោះធម្មជាតិនានា ដែលទាក់ទងនឹងអាកាសធាតុ និងផលប៉ះពាល់នៃគ្រោះធម្មជាតិទាំងនេះដែលពួក

គាត់បានជួបប្រទះកន្លងមក។ បន្ទាប់មក អ្នកសម្របសម្រួល ត្រូវយកព័ត៌មានទាំងនេះទៅបំពេញនៅក្នុងទម្រង់ខាងក្រោមត្រង់កូឡោន "**ប្រភេទគ្រោះធម្មជាតិ**" (ដូចមានក្នុងទម្រង់ខាងក្រោម)។

- **ជំហានទី២** ៖ ក្នុងជំហាននេះ អ្នកសម្របសម្រួលត្រូវបន្តសាកសួរអ្នកចូលរួម ដើម្បីធ្វើចំណាត់ថ្នាក់ភាពងាយរងគ្រោះដែលបានជួបប្រទះក្នុងអំឡុងនៃចន្លោះឆ្នាំ ស្របតាមប្រភេទគ្រោះធម្មជាតិនីមួយៗ។ ក្នុងការធ្វើចំណាត់ថ្នាក់នេះត្រូវដាក់ពិន្ទុពី ១ ដល់ ៥ ស្របតាមកម្រិតនៃភាពរងគ្រោះនីមួយៗ (ពិន្ទុ១ គឺកម្រិតនៃភាពរងគ្រោះទាបបំផុត និងពិន្ទុ ៥ គឺកម្រិតនៃភាពរងគ្រោះធ្ងន់ធ្ងរបំផុត)។
- **ជំហានទី៣** ៖ បន្ទាប់ពីបានពិន្ទុកម្រិតនៃភាពរងគ្រោះនានា ត្រូវពិនិត្យមើលនិន្នាការនៃផលប៉ះពាល់ទៅតាមមុខសញ្ញានីមួយៗ ដើម្បីកំណត់នូវមុខសញ្ញាគ្រោះថ្នាក់ដែលកើតឡើងញឹកញាប់ និងកាន់តែធ្ងន់ធ្ងរ។

## ទម្រង់វិភាគនិន្នាការ

| ប្រភេទ | ឆ្នាំទទួលផលប៉ះពាល់ | | | | សម្គាល់ |
|---|---|---|---|---|---|
| | 1993-1998 | 1999-2004 | 2005-2009 | 2010-2015 | |
| រាំងស្ងួត | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | |
| រដូវប្រាំងអូសបន្លាយ (លើសពី៣សប្តាហ៍) | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | |
| ការខូចខាតដំណាំដោយភាពរាំងស្ងួត | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | |
| ការខូចខាតដំណាំ | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | |
| ដោយទឹកជំនន់ | | | | | |
| ការអូសបន្លាយនៃរយៈពេលទឹកជំនន់លិច | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | |
| ការប្រែប្រួលអំឡុងពេលរដូវប្រាំង-វស្សា | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | |
| ។ល។ | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | 1 2 3 4 5 | |



**សម្គាល់** ៖ ក្នុងការអនុវត្តការវិភាគនិន្នាការជាក់ស្តែង ត្រូវយកចិត្តទុកដាក់លើខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- **ប្រភេទគ្រោះធម្មជាតិ** គឺប្រភេទគ្រោះធម្មជាតិដែលបានកើតមានឡើងជាក់ស្តែងនៅក្នុងមូលដ្ឋាននីមួយៗ។
- **ឆ្នាំទទួលផលប៉ះពាល់** គឺអាចកំណត់ ឬបែងចែកតាមឆ្នាំ ឬតាមជំនាន់ ឬតាមសម័យកាល ឬរបប ឬតាមការកំណត់ផ្សេងៗទៀត ដែលជាអាចធ្វើឲ្យអ្នកចូលរួមងាយស្រួលក្នុងការរំលឹកឡើងវិញនូវព្រឹត្តិការណ៍ និងនិន្នាការនានាពាក់ព័ន្ធនឹងប្រភេទនៃគ្រោះធម្មជាតិនីមួយៗ។

ឧបសម្ព័ន្ធទី២

## ការរៀបចំផែនទីសេវាសង្គម

ផែនទីសេវាសង្គម គឺជាឧបករណ៍មួយសម្រាប់កំណត់អំពីទីតាំងនៃអ្នកផ្តល់សេវា និងទីតាំងនៃអ្នកទទួលសេវា ព្រមទាំងបង្ហាញអំពីបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការផ្តល់ និងការទទួលបាននូវសេវាទាំងនោះ។ លើសពីនេះទៀត ការរៀបចំផែនទីសេវាសង្គមក៏ផ្តល់នូវព័ត៌មានសម្រាប់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋអំពីប្រភពធនធាន និងសេវាកម្មនានាដែលមាននៅក្នុងមូលដ្ឋានរបស់ខ្លួនផងដែរ។

ជារួម តាមរយៈការរៀបចំផែនទីសេវាសង្គម ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ផ.ថ. ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាអាចដឹងអំពីព័ត៌មាននៅក្នុងមូលដ្ឋានរបស់ខ្លួនដូចជា សេវាសំខាន់ៗដែលមាន ឬមិនទាន់មាន ចំនួនគ្រួសារងាយរងគ្រោះ និងគ្រួសារក្រីក្រណាខ្លះដែលបានទទួល ឬមិនបានទទួលនូវសេវាសង្គមចាំបាច់សម្រាប់ពួកគាត់ ឬគ្រួសារដែលត្រូវការជំនួយចាំបាច់បន្ថែមទៀតដូចជា គ្រួសារមានកុមារកំព្រា គ្រួសារមានសមាជិកឈឺជំងឺរ៉ាំរ៉ៃ រួមទាំងអ្នកផ្ទុកមេរោគអេដស៍ គ្រួសារមានកុមារពិការ ឬជនពិការក្នុងបន្ទុក។ល។ ជាមួយគ្នានេះដែរ ផែនទីសេវាសង្គមផ្តោតជាសំខាន់លើព័ត៌មានអំពីតម្រូវការនានារបស់ស្ត្រី និងកុមារដែលងាយរងគ្រោះជាងគេដូចជា កុមារគ្មានអ្នកបីបាច់ថែរក្សា កុមារកំព្រា កុមារពិការ និងស្ត្រីជាមេគ្រួសារ។ ផែនទីសេវាសង្គមក៏ផ្តល់នូវព័ត៌មានបន្ថែមលើទិន្នន័យឃុំ សង្កាត់ដែលមានស្រាប់អំពីគ្រួសារ និងអត្តសញ្ញាណគ្រួសារក្រីក្រ។



ក្នុងកិច្ចដំណើការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ គ.ផ.ថ. អាចរៀបចំ និងប្រើប្រាស់ផែនទីសេវាសង្គម ដើម្បីកំណត់បញ្ហា និងតម្រូវការនានារបស់ប្រជាពលរដ្ឋ តាមរយៈការវិភាគអំពីប្រភេទសេវានានា ដែលបានផ្តល់ជូនប្រជាពលរដ្ឋ គុណភាពនៃការផ្តល់សេវា កម្រិតនៃការចូលរួមទទួលសេវារបស់ប្រជាពលរដ្ឋ កង្វះខាតសេវាដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានាដែលប្រជាពលរដ្ឋ ជាពិសេសជនក្រីក្រ ជនពិការ និងជនងាយរងគ្រោះកំពុងជួបប្រទះ ដែលទាមទារឲ្យមានដំណោះស្រាយសមស្របនានាសម្រាប់ពួកគាត់។

ដើម្បីរៀបចំផែនទីសេវាសង្គម ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ផ.ថ. និងអ្នកពាក់ព័ន្ធនានា ត្រូវយកចិត្តទុកដាក់ និងអនុវត្តតាមសកម្មភាពសំខាន់ៗដូចខាងក្រោម ៖

- ការត្រៀមសម្រាប់ការរៀបចំផែនទីសេវាសង្គម
- ការរៀបចំផែនទីសេវាសង្គមនៅថ្នាក់ភូមិ
- ការវិភាគផែនទីសេវាសង្គម
- ការកំណត់អាទិភាពសម្រាប់ការកសាងផែនការ
- ការប្រើប្រាស់ផែនទីសេវាសង្គម

### ១. ការត្រៀមសម្រាប់ការរៀបចំផែនទីសេវាសង្គម

ការរៀបចំផែនទីសេវាសង្គម គឺជាសកម្មភាពដែលត្រូវមានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។ ដូច្នេះ ដើម្បីធានាឲ្យកិច្ចដំណើរការនៃការរៀបចំផែនទីសេវាសង្គម នៅថ្នាក់ភូមិប្រព្រឹត្តទៅ

ដោយរលូន និងប្រកបដោយប្រសិទ្ធភាព ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ផ.ថ. និងអ្នកពាក់ព័ន្ធនានា ត្រូវត្រៀមរៀបចំជាមុនដូចខាងក្រោម ៖

- ការរៀបចំសម្ភារៈនានាដែលត្រូវប្រើប្រាស់ដូចជា ទម្រង់សូចនាករសេវាសង្គម ក្រដាសផ្ទាំងធំ ហ្វឺត ក្រដាសកាត ក្រដាសពណ៌ សៀវភៅសរសេរ ខិត្តប័ណ្ណ ឬប័ណ្ណផ្សេងៗ ពាក់ព័ន្ធនឹងព័ត៌មានស្តីពីសេវាសង្គម ផែនទីរដ្ឋបាលឃុំ សង្កាត់។ល។
- ការណែនាំដល់ក្រុមការងារដូចជា ការណែនាំអំពីរបៀបពិនិត្យមើលផែនទី របៀបគូសផែនទី របៀបកំណត់ទីតាំងកន្លែងផ្តល់សេវាសង្គមនានា និងរបៀបកត់ត្រាជាដើម។
- ការបែងចែកតួនាទី ភារកិច្ច មុនចាប់ផ្តើមអនុវត្តការគូសផែនទីសេវាសង្គមនៅតាមភូមិ មេឃុំ ចៅសង្កាត់ត្រូវបែងចែកតួនាទី ភារកិច្ចរបស់ក្រុមសម្របសម្រួលដូចជា អ្នកសម្របសម្រួល ជំនួយការសម្របសម្រួល និងអ្នកកត់ត្រាជាដើម។
- ការកំណត់កាលបរិច្ឆេទ ទីកន្លែង និងអ្នកចូលរួម។

## ២. ការរៀបចំផែនទីសេវាសង្គមនៅថ្នាក់ភូមិ

**សកម្មភាពសំខាន់ៗក្នុងពេលប្រជុំជាក់ស្តែងនៅតាមភូមិ ៖**

- អ្នកសម្របសម្រួលស្វាគមន៍អ្នកភូមិ ដែលចូលរួមកិច្ចប្រជុំ និងធ្វើការណែនាំខ្លួន
- ពន្យល់ពីគោលបំណងនៃកិច្ចប្រជុំនៅថ្នាក់ភូមិ និងគោលបំណងនៃការរៀបចំផែនទីសេវាសង្គម



- បង្ហាញទម្រង់សូចនាករទាំង១៧ ដែលបានរៀបចំនៅលើក្រដាសផ្ទាំងធំដែលរួមមាន ៖
  1. ខ្នងផ្ទះដែលមានទារកទើបនឹងកើត ប៉ុន្តែមិនទាន់មានសំបុត្រកំណើត
  2. ខ្នងផ្ទះមានកូនអាយុ៩ ទៅ ១២ខែដែលមិនធ្លាប់បានទទួលថ្នាំបង្ការពេញលេញ
  3. ខ្នងផ្ទះមានម្តាយ ដែលមិនធ្លាប់សម្រាលកូននៅមន្ទីរពេទ្យ (មណ្ឌលសុខភាព និងមន្ទីរពេទ្យ)
  4. ខ្នងផ្ទះមានកូនអាយុចាប់ពី ៣ ទៅ ៤ ឆ្នាំ មិនបានចូលរៀនក្នុងសាលាមត្តេយ្យរដ្ឋ សាលាមត្តេយ្យឯកជន ឬសាលាមត្តេយ្យសហគមន៍
  5. ខ្នងផ្ទះមានកុមារអាយុ ៥ ឆ្នាំ ដែលមិនបានចូលសិក្សាក្នុងសាលាមត្តេយ្យរដ្ឋ សាលាមត្តេយ្យឯកជន ឬសាលាមត្តេយ្យរបស់សហគមន៍
  6. ខ្នងផ្ទះមានកុមារអាយុ៦ឆ្នាំ ដែលមិនបានចូលរៀនក្នុងសាលាបឋមសិក្សារដ្ឋ សាលាបឋមសិក្សាឯកជន ឬសាលាបឋមសិក្សាសហគមន៍
  7. ខ្នងផ្ទះមានកុមារអាយុចាប់ពី ៧ដល់១១ឆ្នាំ មិនបានចូលរៀនក្នុងសាលាបឋមសិក្សារដ្ឋ ឬឯកជន
  8. ខ្នងផ្ទះមានកុមារអាយុចាប់ពី១២ដល់១៤ឆ្នាំ ដែលមិនបានចូលរៀនក្នុងសាលាបឋមសិក្សា អនុវិទ្យាល័យ ឬវិទ្យាល័យរដ្ឋ ឬឯកជន

9. ខ្នងផ្ទះមានកុមារធ្វើការពាក់ព័ន្ធនៅក្នុងការងារ ដែលគ្រោះថ្នាក់ និងប៉ះពាល់ដល់សុខភាព
10. ខ្នងផ្ទះដែលមិនបានប្រើប្រាស់ប្រភពទឹកស្អាត
11. ខ្នងផ្ទះគ្មានបង្គន់អនាម័យ ឬមានបង្គន់ដែរ ប៉ុន្តែមិនមានលក្ខណៈបច្ចេកទេស
12. ខ្នងផ្ទះមានកុមារកំព្រា ឬកុមារដែលត្រូវបានគេបោះបង់ចោល (កុមារពុំមានអ្នកបីបាច់ថែរក្សា)
13. ខ្នងផ្ទះមានមេគ្រួសារជាស្ត្រី
14. ខ្នងផ្ទះមានសមាជិកគ្រួសារមានជំងឺរ៉ាំរ៉ៃ
15. ខ្នងផ្ទះមានកុមារពិការភាពផ្នែកសតិបញ្ញា និងរាងកាយ
16. ខ្នងផ្ទះមានបញ្ហាសន្តិសុខស្បៀង (ពឹងផ្អែកលើការខ្ចីបុលស្រូវអង្ករគេរយៈពេលបីខែ ឬច្រើនខែក្នុងរយៈពេល១២ខែចុងក្រោយ)
17. ខ្នងផ្ទះមានប័ណ្ណក្រីក្រ (អត្តសញ្ញាណកម្មគ្រួសារក្រីក្រ)

- អ្នកសម្របសម្រួលបន្តពិភាក្សា ដើម្បីផ្តល់ការយល់ដឹងដល់អ្នកភូមិអំពីសូចនាករនីមួយៗ។
- អ្នកសម្របសម្រួលបន្តពិភាក្សា និងគូសគំនូសព្រាងផែនទីឃុំ សង្កាត់ និងកំណត់ឲ្យបានច្បាស់អំពីទីតាំងផ្តល់សេវាសង្គមនានាដែលមាននៅក្នុងមូលដ្ឋានរបស់ខ្លួន។ បន្ទាប់មកត្រូវសម្របសម្រួល និងពិភាក្សាអំពីទីតាំងនៃខ្នងផ្ទះ



របស់ប្រជាពលរដ្ឋតាមសូចនាករនានាខាងលើ និងគូសគំនូសតាងខ្នងផ្ទះទាំងនោះលើផែនទីដែលបានរៀបចំ។

- សួរបញ្ជាក់អ្នកភូមិអំពីភាពត្រឹមត្រូវនៃទីតាំងខ្នងផ្ទះ អគារសាធារណៈ កន្លែងផ្តល់សេវា។ល។
- ដើម្បីឲ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ផែនទីសេវាសង្គមត្រូវមានព្រំប្រទល់ មានសញ្ញាសម្គាល់ ទីតាំងធនធាន និងសេវា សញ្ញាប្រាប់ទិស លេខកូដខ្នងផ្ទះ និងសូចនាករ និងមានកំណត់ត្រាអំពីមូលហេតុសំខាន់ៗ ដែលខ្នងផ្ទះនីមួយៗមិនទទួលបានសេវា។ល។



## ៣. ការវិភាគផែនទីសេវាសង្គម

បន្ទាប់ពីគូសគំនូសព្រាងផែនទីសេវាសង្គមហើយ អ្នកសម្របសម្រួលត្រូវបន្តវិភាគផែនទីសេវាសង្គម។ ការវិភាគនេះ មានគោលបំណង ដើម្បីឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានាបានយល់ច្បាស់អំពីស្ថានភាពក្នុងការទទួលសេវាសង្គមដូចជា បញ្ហា ឬការលំបាកនានា និងព័ត៌មានលម្អិតនៃសេវាសង្គមនានាដែលមាននៅក្នុងភូមិ និងសូចនាករនៃបញ្ហា ឬសគល់នៃបញ្ហា និងតម្រូវការនានារបស់គ្រួសារងាយរងគ្រោះ។

តាមរយៈការវិភាគផែនទីសេវាសង្គម ក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានាបានដឹងអំពីប្រភេទសេវាសង្គម ដែលមាននៅក្នុងមូលដ្ឋានរបស់ខ្លួន និងស្ថានភាពនៃការទទួលបាននូវសេវាទាំងនោះ ជាពិសេស ការទទួលបានសេវារបស់គ្រួសារក្រីក្រ និងការលំបាកនានាដែលគ្រួសារក្រីក្រមួយចំនួនជួបប្រទះក្នុងការទទួលសេវាសង្គម។ ផ្អែកលើលទ្ធផលនៃការវិភាគនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ គ.ផ.ថ. អាចកំណត់បាននូវមធ្យោបាយ ឬវិធានការនានា ដើម្បីជួយគ្រួសារក្រីក្រទាំងនោះទទួលបាននូវសេវាសង្គមនានាដែលមានស្រាប់ និងអាចកំណត់អំពីគ្រួសារក្រីក្រទាំងឡាយដែលត្រូវការការគាំទ្រមុនគេ។

ក្នុងកិច្ចដំណើរការនៃការវិភាគព័ត៌មាន នៅលើផែនទីសេវាសង្គម អ្នកសម្របសម្រួល អាចប្រើប្រាស់សំណួរសំខាន់ៗមួយចំនួនជាជំនួយដូចមានខាងក្រោម ដើម្បីធ្វើការវិភាគទិន្នន័យដែលមាននៅលើផែនទីសេវាសង្គម។



- តើនរណា ឬក្រុមគ្រួសារមួយណាដែលត្រូវបានកំណត់ថាជាក្រុមគោលដៅ? ហេតុអ្វី?
- តើសហគមន៍ ឬខ្នងផ្ទះមួយណាដែលកំពុងរស់នៅឆ្ងាយពីទីតាំងផ្តល់សេវា?
- តើមានសេវាណាខ្លះដែលគេមិនសូវបានប្រើប្រាស់?
- តើសេវាណាខ្លះដែលមិនមាននៅក្នុងភូមិ?
- ហេតុអ្វីបានជាគ្រួសារមិនបានប្រើប្រាស់ ឬទទួលសេវា?
- តើមានសេវាណាខ្លះអាចរកបាននៅក្នុងភូមិ?
- តើប្រជាជនដឹងពីសារៈសំខាន់នៃសេវានោះដែរឬទេ?
- តើគ្រួសារនីមួយៗត្រូវមានធនធានអ្វីខ្លះ?
- តើត្រូវដាក់បញ្ចូលបញ្ហាប្រឈមនានា ដែលពាក់ព័ន្ធនឹងសេវាសង្គមទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់យ៉ាងដូចម្តេច?
- តើអ្នកណាខ្លះ ជាអ្នកពាក់ព័ន្ធសំខាន់ៗនៅក្នុងបញ្ហាសេវាសង្គមនីមួយៗ?
- តើនរណា ឬគ្រួសារណា ដែលងាយទទួលហានិភ័យនៃគ្រោះមហន្តរាយទាំងនេះ? តើត្រូវធ្វើអ្វីខ្លះ?
- តើមានតំបន់សុវត្ថិភាពគ្រប់គ្រាន់ សម្រាប់ប្រមូលផ្តុំគ្រួសារដែលនៅក្នុងតំបន់ងាយរងគ្រោះដោយទឹកជំនន់ដែរឬទេ?
- តើមានកន្លែងដែលមានសុវត្ថិភាពផ្សេងទៀតដែរឬទេ?
- តើស្ថានភាពទឹក និងអនាម័យមានលក្ខណៈដូចម្តេចនៅតំបន់នោះ?

## ៤. ការកំណត់អាទិភាពសម្រាប់ការរៀបចំផែនការ

ផ្អែកលើលទ្ធផលនៃការវិភាគផែនទីសេវាសង្គម ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ផ.ថ. និងអ្នកពាក់ព័ន្ធនានាកំណត់បាននូវបញ្ហា តម្រូវការ និងដំណោះស្រាយនានា។ ដូច្នេះ ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ គ.ផ.ថ. អាចប្រើប្រាស់ព័ត៌មានទាំងនេះជាធាតុចូល ក្នុងការរៀបចំជាគម្រោងវិនិយោគនានា សម្រាប់ដាក់បញ្ចូលទៅក្នុងបញ្ជីតម្រូវការគម្រោង ឬរៀបចំយុទ្ធសាស្ត្រនានាសម្រាប់ដោះស្រាយបញ្ហាទាំងនោះ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

## ៥. ការប្រើប្រាស់ផែនទីសេវាសង្គម

ក្រៅពីការប្រើប្រាស់ផែនទីសេវាសង្គមសម្រាប់ការវិភាគ និងការរៀបចំគម្រោងវិនិយោគ និងការចាត់វិធានការនានា ដើម្បីលើកកម្ពស់ការផ្តល់សេវាសង្គមជូនប្រជាពលរដ្ឋ ផែនទីសេវាសង្គមក៏អាចប្រើប្រាស់ជាឧបករណ៍ សម្រាប់ការត្រួតពិនិត្យតាមដានអំពីវឌ្ឍនភាពនៃការផ្តល់ និងការទទួលបាននូវសេវាសង្គមនានានៅថ្នាក់មូលដ្ឋានផងដែរ។ ដូច្នេះ ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ផ.ថ. និងអ្នកពាក់ព័ន្ធនានា ត្រូវរៀបចំ និងធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គមនេះជាប្រចាំ។ តាមរយៈការផ្តល់អន្តរាគមន៍នានា ផែនទីសេវាសង្គមដែលបានធ្វើបច្ចុប្បន្នភាព នឹងបង្ហាញឲ្យឃើញអំពីការផ្លាស់ប្តូរនៃខ្នងផ្ទះដែលជួបបញ្ហា គុណភាពនៃការផ្តល់សេវា កម្រិតនៃការចូលរួមទទួលសេវាជាពិសេស ការចូលរួមទទួលសេវារបស់គ្រួសារក្រីក្រជាដើម។



## ឧបសម្ព័ន្ធទី៣

### ការរៀបចំប្រតិទិនរដូវកាល
(ពេលវេលា សម្ភារៈ និងជំនាញចាំបាច់)

ជាទូទៅ ការរៀបចំប្រតិទិនរដូវកាល ត្រូវចំណាយរយៈពេលប្រមាណពី១-២ម៉ោង ឬអាចច្រើនជាងនេះ អាស្រ័យលើប្រធានបទដែលត្រូវពិភាក្សា និងចំណេះដឹង បទពិសោធន៍របស់អ្នកចូលរួម។

សម្ភារៈនានា ដែលត្រូវការសម្រាប់ការរៀបចំប្រតិទិនរដូវកាលមានដូចជា ប៊ិចហ្វឺត ក្រដាសផ្ទាំងធំៗ សៀវភៅ ប៊ិច និងក្រដាស A4។ល។ អ្នកសម្របសម្រួល ក៏អាចគូសព្រាងប្រតិទិនរដូវកាលនេះនៅលើដី បន្ទាប់មកត្រូវចម្លងចូលលើក្រដាសផ្ទាំងធំ។ អ្នកកត់ត្រាត្រូវធ្វើកំណត់ហេតុនៃការពិភាក្សានេះឱ្យបានច្បាស់លាស់។

សមាភាពចូលរួមពិភាក្សារៀបចំប្រតិទិនរដូវកាលរួមមាន អ្នកសម្របសម្រួល អ្នកអង្កេតការ ឬអ្នកកត់ត្រា និងអ្នកចូលរួមនៅមូលដ្ឋាន (អ្នកភូមិ) ដែលបានជ្រើសរើស។ អ្នកសម្របសម្រួល និងអ្នកអង្កេតការ ឬកត់ត្រា ត្រូវមានបទពិសោធន៍ទាំងការប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្រដែលមានការចូលរួម និងជំនាញសម្របសម្រួល។

## វិធីសាស្ត្រ

ក្នុងការរៀបចំប្រតិទិនរដូវកាល ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ផ.ថ. និងអ្នកពាក់ព័ន្ធនានា ត្រូវអនុវត្តតាមជំហាននានាដូចខាងក្រោម ៖

- <u>ជំហានទី១</u> ៖ **ការជ្រើសរើសអ្នកចូលរួម**។ ជាដំបូងត្រូវ

ធ្វើការកំណត់ និងការជ្រើសរើសអ្នកចូលរួមនៅមូលដ្ឋានដែលមានបទពិសោធន៍ និងចំណេះដឹងមួយចំនួន ដើម្បីពិភាក្សាជាទូទៅលើប្រធានបទ ដែលត្រូវយកមកពិភាក្សាជាមួយអ្នកចូលរួមទាំងអស់។ ការធ្វើបែបនេះ អាចមានសារៈប្រយោជន៍សម្រាប់ក្រុមផ្សេងទៀត ដែលត្រូវបង្កើតឡើងដើម្បីធ្វើការពិភាក្សា។ ជាការប្រសើរ អ្នកចូលរួមទាំងអស់គួរបែងចែកជាក្រុមតូចៗ ដែលមានសមាជិកពី៥ទៅ១០នាក់។ ការបែងចែកក្រុមពិភាក្សានេះ គួរធ្វើឡើង ស្របតាមប្រភេទក្រុមប្រជាពលរដ្ឋនានា ដែលមាននៅក្នុងសង្គម ឬសហគមន៍ និងទាក់ទងនឹងប្រធានបទសំខាន់ៗដែលត្រូវពិភាក្សា។ ឧទាហរណ៍ ក្រុមពិភាក្សាទាំងនោះអាចបែងចែកតាមភេទ តាមស្ថានភាពសុខភាព តាមកម្រិតចំណូល តាមអាយុ ឬជីវភាពរស់នៅ។ល។

- <u>**ជំហានទី២**</u> **៖ ការណែនាំ និងការពន្យល់**។ នៅពេលធ្វើការជាមួយក្រុមពិភាក្សានីមួយៗ អ្នកសម្របសម្រួល និងអ្នកអង្កេតការ ឬកត់ត្រា ត្រូវចាប់ផ្តើមដោយធ្វើការណែនាំខ្លួនឯង និងពន្យល់ឲ្យបានច្បាស់លាស់អំពីគោលបំណងនៃការពិភាក្សា។ ជាមួយគ្នានេះដែរ អ្នកសម្របសម្រួល ត្រូវបញ្ជាក់ និងធានាថា អ្នកចូលរួមទាំងអស់យល់ច្បាស់ និងពេញចិត្តជាមួយនឹងប្រធានបទដែលត្រូវពិភាក្សា។



- <u>**ជំហានទី៣**</u> **៖ ការរៀបចំប្រតិទិនរដូវកាល**។ ប្រតិទិនរដូវកាល ត្រូវឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងរបស់សហគមន៍ ដូចជា ចំណេះដឹង និងផ្នត់គំនិតរបស់អ្នកភូមិអំពីពេលវេលា រដូវកាល និងព្រឹត្តិការណ៍នានាជាដើម។ ដូច្នេះ អ្នកសម្របសម្រួលត្រូវពិភាក្សា និងសាកសួរអ្នកចូលរួមអំពីរដូវកាលសំខាន់ៗដែលមានក្នុងឆ្នាំនីមួយៗ និងសរសេរដាក់នៅលើក្រដាសផ្ទាំងធំនៅផ្នែកខាងលើ ឬសរសេរនៅលើផ្ទៃដីក៏បាន។ គេអាចប្រើប្រាស់និមិត្តសញ្ញាផ្សេងៗដើម្បីសម្គាល់រដូវកាល។ ក្នុងករណី អ្នកចូលរួមស្គាល់ឈ្មោះខែនានាក្នុងឆ្នាំ គេអាចសរសេរ ឬដៅនិមិត្តសញ្ញាសម្គាល់ពីក្រោមរដូវកាលទាំងនោះ ដើម្បីឲ្យស៊ីសង្វាក់គ្នាជាមួយរដូវកាលធំៗ។ ក្នុងករណីចាំបាច់ អ្នកចូលរួមអាចពិនិត្យមើលកម្មវិធី ឬទិវានានាដែលត្រូវរៀបចំនៅក្នុងសហគមន៍ក្នុងឆ្នាំនីមួយៗដូចជា ពិធីបុណ្យនានា ឬវដ្តនានាដូចជា ការផលិតស្បៀងជាដើម។ ជាទូទៅ ប្រតិទិនរដូវកាល ត្រូវរៀបចំសម្រាប់រយៈពេលយ៉ាងតិច១ឆ្នាំ (ឬរយៈពេលវែងជាងនេះតាមការចាំបាច់) ដើម្បីជួយសម្រួលក្នុងការពិភាក្សា និងកំណត់បញ្ហា ឬបាតុភូត ឬព្រឹត្តិការណ៍ពាក់ព័ន្ធនឹងរដូវកាល។ ជាមួយគ្នានេះដែរ អ្នកសម្របសម្រួល ត្រូវទុកកន្លែងទំនេរនៅផ្នែកខាងឆ្វេងនៃក្រដាសផ្ទាំងធំ ដើម្បីកត់ត្រាបញ្ហា ឬបាតុភូតនានាដែលកំពុងធ្វើ

ការសិក្សាស្រាវជ្រាវ ឬព្រឹត្តិការណ៍ផ្សេងទៀត ដែលអ្នកចូលរួមយល់ថាមានសារៈសំខាន់។ បន្ទាប់មក អ្នកសម្របសម្រួល ត្រូវសាកសួរអ្នកចូលរួមអំពីការផ្លាស់ប្តូរសំខាន់ៗក្នុងជីវភាពរស់នៅរបស់ពួកគាត់ ទៅតាមរដូវកាលនីមួយៗដែលបានកំណត់។ ជាគោលការណ៍ ការពិភាក្សាត្រូវផ្តោតជាសំខាន់លើប្រធានបទដែលត្រូវពិភាក្សា ប៉ុន្តែពុំគួរកម្រិតត្រឹមតែចំណុចទាំងនេះនោះទេ។ ក្នុងការពិភាក្សា អ្នកសម្របសម្រួល ត្រូវជំរុញ និងលើកទឹកចិត្តឱ្យអ្នកចូលរួមសរសេរ ឬគូររូប ឬធ្វើនិមិត្តសញ្ញាសម្គាល់បញ្ហា ឬបាតុភូតនៅផ្នែកខាងឆ្វេងនៃក្រដាសផ្ទាំងធំ (ឬនៅលើដី) រួចដាក់បង្ហាញឲ្យអ្នកចូលរួមទាំងអស់គ្នាបានឃើញ។ អ្នកសម្របសម្រួលត្រូវធានាថា អ្នកចូលរួមយល់ច្បាស់អំពីអ្វីដែលបានបង្ហាញ និងពន្យល់អំពីចំណុចផ្សេងទៀតដែលអាចដាក់បន្ថែមបានតាមការចាំបាច់។ បន្ទាប់ពីបានកំណត់បញ្ហា បាតុភូត ឬព្រឹត្តិការណ៍នានានៃការផ្លាស់ប្តូរជីវភាពរស់នៅ អ្នកសម្របសម្រួលត្រូវយកចំណុចទាំងនេះមកពិភាក្សាម្តងមួយៗ ដោយឲ្យអ្នកចូលរួមមូលដ្ឋានដាក់សញ្ញាសម្គាល់ដូចជា ដុំថ្ម ឈើ គ្រាប់ពូជ កាក់ និងសម្ភារៈផ្សេងទៀតដែលមាន ឬធ្វើការគូសសម្គាល់ខាងក្រោមខែ ឬរដូវកាលនីមួយៗ ដើម្បីធ្វើការកំណត់ចំនួនវិសាភាព ឬស្ថានភាពរបស់បញ្ហាទាំងនោះ។ ឧទាហរណ៍



ការដាក់ដុំថ្ម ឬគំនូសចំនួនច្រើន ដើម្បីកំណត់ខែ ឬរដូវកាលដែលមានភ្លៀងច្រើន ឬដុំថ្មចំនួនតិច ដើម្បីសម្គាល់ខែមានភ្លៀងតិច ឬរដូវប្រាំង។ អ្នកសម្របសម្រួលត្រូវជំរុញ និងលើកទឹកចិត្តអ្នកចូលរួមទាំងអស់រៀបចំទម្រង់ដោយខ្លួនឯងតាមដែលអាចធ្វើទៅបាន។

- <u>ជំហានទី៤</u> **៖ ការវិភាគប្រតិទិនរដូវកាល**។ បន្ទាប់ពីបានកំណត់នូវបញ្ហា ឬព្រឹត្តិការណ៍នានា អ្នកសម្របសម្រួលត្រូវឱ្យអ្នកចូលរួម ពិនិត្យមើលឡើងវិញនូវព្រឹត្តិការណ៍ទាំងនោះ ដើម្បីធានាភាពត្រឹមត្រូវ ភាពសមស្រប និងស៊ីសង្វាក់គ្នាជាមួយនឹងពេលវេលា។ ឧទាហរណ៍ តើការចាប់ផ្តើម និងការបញ្ចប់នៃរដូវកាល សមស្របជាមួយនឹងរបាយ ឬកម្រិតទឹកភ្លៀងតាមខែនីមួយៗដែរឬទេ? តើតម្រូវការកម្លាំងពលកម្មជាបុរសមានការកើនឡើង ឬខែដែលមានប្រាក់ឈ្នួលពលកម្មខ្ពស់ ស្របពេលជាមួយនឹងរយៈពេលនេះឬទេ? តើពលកម្មជានារីមានការកើនឡើងក្រោយពេលការច្រូតកាត់ដែរឬទេ? តើថ្លៃឈ្នួលពលកម្មដែលថយចុះនៅពេលច្រូត ហើយចាប់ផ្តើមឡើងវិញដែរឬទេ? ប្រសិនមិនដូច្នេះទេ តើមានមូលហេតុអ្វី? ប្រសិនបើអាចធ្វើបាន គួរពិនិត្យមើលដោយប្រៀបធៀបជាមួយនឹងប្រភពទិន្នន័យផ្សេងទៀតដែលមាន។ ឧទាហរណ៍ តើទិន្នន័យទាំងនោះស្របគ្នានឹងព័ត៌មាន ដែលបានកត់ត្រា

ក្នុងឧបករណ៍វិភាគផ្សេងទៀត ឬទិន្នន័យដែលមានស្រាប់ឬទេ? បើខុសគ្នា តើមានមូលហេតុអ្វីខ្លះ? ប្រសិនបើប្រតិទិនរដូវកាលនេះ ត្រូវបានបង្ហាញជូនក្រុមផ្សេងទៀត ដើម្បីពិនិត្យ និងផ្តល់យោបល់ តើមានមតិខុសគ្នាច្រើនដែរឬទេ? តើគំនិតខុសគ្នានេះ អាចរកការមូលមតិគ្នាបានដែរឬទេ? ជាមួយគ្នានេះដែរ អ្នកសម្របសម្រួលត្រូវស្នើសុំឲ្យអ្នកចូលរួម កំណត់នូវពេលវេលាដែលមានហានិភ័យខ្ពស់ក្នុងឆ្នាំ និងវិធីសាស្ត្រនានាដែលត្រៀមទុក និងឆ្លើយតបចំពោះហានិភ័យទាំងនោះ។ (ព័ត៌មានទាំងនេះ អាចរៀបចំក្នុងទម្រង់ស្តីពីការគ្រប់គ្រងហានិភ័យ)។ អ្នកចូលរួម ក៏ត្រូវពិនិត្យអំពីភាពពាក់ព័ន្ធគ្នា ឬទំនាក់ទំនងនៃហេតុផលរវាងបាតុភូតរដូវកាល និងឧប្បត្តិហេតុផ្សេងៗ។ ឧទាហរណ៍ ទំនាក់ទំនងរវាងអាកាសធាតុជាមួយនឹងការកើតឡើងនូវជំងឺផ្សេងៗ កម្រិតកិច្ចការនៅផ្ទះជាមួយនឹងអត្រាឈប់រៀន។ ការពិនិត្យនេះ ក៏អាចផ្តល់ឱកាស ដើម្បីធ្វើការពិភាក្សាអំពីផលប៉ះពាល់នានាតាមរដូវកាលលើការផ្លាស់ប្តូរគោលនយោបាយ ឬការអនុវត្តរួមបញ្ចូលទាំងផលប៉ះពាល់ តាមរដូវកាលនៃការផ្លាស់ប្តូរគោលនយោបាយ ឬការអនុវត្តលើព្រឹត្តិការណ៍ផ្សេងៗ។

- <u>**ជំហានទី៥**</u> **៖ ការបូកសរុប។** ផ្អែកលើលទ្ធផលនានានៃកិច្ចពិភាក្សាខាងលើ ពិសេសលទ្ធផលក្នុងជំហានទី២ និងជំហានទី៣ អ្នកសម្របសម្រួលត្រូវបូកសរុប និងរៀបចំលទ្ធផលនៃការរៀបចំប្រតិទិនរដូវកាល ដោយស្នើសុំឲ្យអ្នកចូលរួមធ្វើការចម្លងតារាងប្រតិទិនរដូវកាល ដែលបានរៀបចំនៅលើក្រដាសផ្ទាំងធំ ទៅលើក្រដាសដែលមានទំហំសមស្របសម្រាប់ក្រុមកសាងផែនការ។ បន្ទាប់មកត្រូវពិនិត្យមើលម្តងទៀត ដើម្បីធានាថា អ្នកចូលរួមទាំងអស់យល់ដឹងអំពីព័ត៌មាន ដែលត្រូវប្រើប្រាស់។ ជាមួយគ្នានេះដែរ ត្រូវស្នើឱ្យអ្នកចូលរួមធ្វើការឆ្លុះបញ្ចាំងទៅលើអត្ថប្រយោជន៍ គុណវិបត្តិ និងសក្តានុពលភាពនានានៃឧបករណ៍។ នៅចុងបញ្ចប់ ត្រូវអរគុណអ្នកចូលរួមនានាដែលបានចំណាយពេលវេលា កម្លាំងកាយ និងកម្លាំងចិត្តខិតខំប្រឹងប្រែងចូលរួម និងរៀបចំប្រតិទិនរដូវកាលនេះ។

## ចំណុចគួរចងចាំ

ជំនាញសម្របសម្រួល មានសារសំខាន់ណាស់សម្រាប់ការរៀបចំកិច្ចប្រជុំពិភាក្សា ដើម្បីរៀបចំប្រតិទិនរដូវកាល។ វិធីសាស្ត្រដែលបានរៀបរាប់ខាងលើ គឺជាការណែនាំទូទៅ។ អាស្រ័យហេតុនេះ អ្នកសម្របសម្រួល ត្រូវចេះបត់បែនក្នុងការប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្រទាំងនេះ ស្របតាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាន និងតម្រូវការចាំបាច់។

សហការរៀបរៀងដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និង

កម្មវិធីស្បៀងអាហារពិភពលោកកម្ពុជា

គាំទ្រដោយ Mekong ARCC